អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 26-Jul-2013, 13:03

CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី២១៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លោក រ៉ូជឺ ហ្វីលីព

*(Mr. Roger Phillips)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី

*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Dale LYSAK)*

លោក វីល្លៀម ស្មីត *(Mr.William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ*(Ms.Anta GUISSE)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

កញ្ញា បេនី យេ *(Ms. Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ដេល លីសាក់ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ូណូហ្វត | បារាំង |
| លោក ស សារិន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនៅមានបញ្ហាសំខាន់ៗមួយចំនួនដែលត្រូវដោះស្រាយនៅក្នុងសំណុំរឿង០០២/០១ ដែលបញ្ហាខ្លះភាគីទើបតែបានលើកឡើងនៅនាទីចុងក្រោយអម្បាញ់មិញនេះប៉ុណ្ណោះ។

ហើយជាបឋម អង្គជំនុំជម្រះនឹងដោះស្រាយទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើឱ្យសុំកោះហៅសាក្សីបន្ថែម ពាក់ព័ន្ធទៅនឹងអង្គហេតុនៅទួលពោធិ៍ជ្រៃ។ ហើយភាគីទាំងអស់នឹងទទួលបាននូវឱកាសក្នុងការឆ្លើយតបទៅនឹងសំណើសុំទាំងនេះ។

ហើយបន្ទាប់មកទៀត អង្គជំនុំជម្រះនឹងពិចារណាទៅលើសេចក្ដីសន្និដ្ឋានរបស់ភាគីទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើង វិញលើសេចក្ដីសម្រេចរបស់ខ្លួនដែលមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស សារិន។

[០៩:០៧:៤៨]

ហើយបន្ទាប់មកទៀត អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាលើកឡើងនូវបញ្ហាចំនួនពីរដែលបានផ្ញើតាមរយៈអ៊ីម៉ែលមកកាន់មន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងកាលពីម្សិលមិញ។ ទី១ បញ្ហាពាក់ព័ន្ធនឹងសំណើសុំឱ្យធ្វើសេចក្ដីសន្និដ្ឋានផ្ទុយប្រឆាំងទៅនឹងជនជាប់ចោទ ខៀវ សំផន និង នួន ជា និងទី២ ពាក់ព័ន្ធទៅនឹងសំណើសុំទទួលយកឯកសារភស្តុតាង និងការដាក់ចំណាត់ថ្នាក់ឯកសារលេខ E3។ ភាគីទាំងអស់នឹងត្រូវបានអនុញ្ញាតឱ្យធ្វើការឆ្លើយតប។

ហើយបន្ទាប់មកទៀត អង្គជំនុំជម្រះកត់សម្គាល់លើសំណើលើកទី៦ របស់មេធាវីការពារក្ដី នួន ជា ដែលបានស្នើសុំឱ្យកោះហៅសាក្សីដែលមានរហស្សនាម TCW-223 ដែលបានដាក់ស្នើសុំកាលពីម្សិលមិញ។ ហើយដោយសារតែសំណើទាំងនេះ គឺគ្រាន់តែជាសំណើធ្វើសាជាថ្មីឡើងវិញប៉ុណ្ណោះ។ ហេតុនេះ អង្គជំនុំជម្រះនឹងមិនស្ដាប់សំណើនេះឡើងវិញទេ ហើយបញ្ហានេះនឹងយកទៅសម្រេចទៅក្នុងសេចក្ដីសម្រេចស្ដីពីសាក្សី។

[០៩:០៩:០៣]

ហើយបន្ទាប់ពីនេះ អង្គជំនុំជម្រះនឹងស្តាប់នូវសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាក់ទងទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលបានស្នើសុំឱ្យកោះហៅសាក្សីដែលពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់នៅក្នុងការវាយប្រហារលើមន្ត្រីសាធារណរដ្ឋខ្មែរ ដែលសំណើនេះទើបតែបានផ្ញើក្រៅផ្លូវការជាបឋមកាលពីម្សិលមិញនេះប៉ុណ្ណោះ។

ហើយជាចុងក្រោយ អង្គជំនុំជម្រះនឹងស្តាប់នូវសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់មេធាវីការពារក្តី ខៀវ សំផន ដែលបានស្នើសុំព័ត៌មានទាក់ទៅនឹងលក្ខខណ្ឌនៃការកោះហៅសាក្សី នូ មោក ឱ្យចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ដែលសំណើនេះទើបតែដាក់ក្រៅផ្លូវការបឋមកាលពីម្សិលមិញ។

ហើយជាចុងក្រោយ អង្គជំនុំជម្រះនឹងផ្តល់នូវការជូនដំណឹងបន្ថែមដល់ភាគីអំពីកាលវិភាគនៃការកំណត់រយៈពេលនៃកាលបរិច្ឆេទចុងក្រោយ។

[០៩:១០:១១]

បាទ ជាបន្តទៅនេះដោយការចាប់ផ្តើម និងសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅសាក្សីបន្ថែមពាក់ព័ន្ធនឹងអង្គហេតុនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះ ស្នើសុំការបញ្ជាក់ពីសហព្រះរាជអាជ្ញាថាតើសហព្រះរាជអាជ្ញាមានអ្វីចង់បន្ថែម ដើម្បីគាំទ្រសារណា ជាលាយលក្ខណ៍អក្សររបស់ខ្លួនដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយនោះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម មេធាវីការពារក្តី និងភាគី។ យើងមិនមានអ្វីបន្ថែមជាសេចក្តីសន្និដ្ឋានបន្ថែមទេនៅពេលនេះ។ ប៉ុន្តែអាស្រ័យទៅលើការឆ្លើយតបរបស់ភាគីទៅនឹងសំណើទាំងអស់នោះ។ ប៉ុន្តែជាកិច្ចចាប់ផ្តើមនេះយើងខ្ញុំមិនទាន់មានសេចក្តីសន្និដ្ឋានអ្វីបន្ថែមទេបាទ។

**ប្រធានអង្គជំនុំ៖**

ចុះខាងភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះបញ្ហានេះ តើមាន ចង់មានមតិយោបល់អ្វីដែរឬទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ចំពោះសំណើស្នើរបស់សហព្រះរាជ

អាជ្ញានៅក្នុងការស្ដាប់សាក្សីបន្ថែមពីររូបនេះ មេធាវីនាំមុខមានការគាំទ្រចំពោះការស្នើសុំនេះ ដោយ-សារសាក្សីដែលស្នើដោយតំណាងសហព្រះរាជអាជ្ញា ផ្ដល់ព័ត៌មានជាក់លាក់ពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅទួលពោធិ៍ជ្រៃ ដោយនិយាយពាក់ព័ន្ធទាំងការដឹកជញ្ជូនបុគ្គលដែលត្រូវយកទៅទួលពោធិ៍ជ្រៃ និងអ្វីដែលកើតឡើងនៅទួលពោធិ៍ជ្រៃ។ ហើយក៏ស្គាល់អំពីរចនាសម្ព័ន្ធផ្សេងៗនៃមេដឹកនាំខ្មែរក្រហមនៅពេលនោះដែលរៀបចំអំពើឧក្រិដ្ឋកម្មដែលកើតឡើងនៅពេលនោះដែរ។ ដូច្នេះ សំណើទាំងពីរនេះជាសំណើដែលសមស្រប ហើយដែលយើងខ្ញុំគាំទ្រ។ បាទ សូមអរគុណលោកប្រធាន។

[០៩:១២:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងក្រុមមេធាវីការពារក្ដី ពីក្រុមមេធាវីការពារក្ដីលោក នួន ជា មុន តើចង់មានមតិយោបល់អ្វីលើកឡើងតបទៅនឹងសំណើសុំរបស់ក្រុមខាងតំណាងសហព្រះរាជអាជ្ញា ដែលបានលើកឡើងអម្បាញ់មិញនេះ ពាក់ព័ន្ធនឹងការស្នើសុំបន្ថែម ស្ដាប់សក្ខីកម្មបន្ថែមពាក់ព័ន្ធជាមួយនឹងហេតុ-ការណ៍នៅទួលពោធិ៍ជ្រៃដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម មេធាវី ហើយនិងសហព្រះរាជអាជ្ញា។ យើងខ្ញុំមិនមានសេចក្ដីសន្និដ្ឋានអ្វីច្រើនទេ ក្រៅពីបញ្ជាក់ថាយើងមានសំណើ យើងបានពិនិត្យដោយចាប់អារម្មណ៍នូវសំណើនេះជាពិសេសក្នុង ទាក់ទងទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញាទៅលើសំណើរបស់យើងខ្ញុំដែលយើងបានស្នើដូចដែលអង្គជំនុំជម្រះ សាក្សី TCW-289 នោះគឺថា នៅក្នុងខ្សែភាពយន្តមួយថ្ងៃនៅទួលពោធិ៍ជ្រៃនោះ គឺថាអាចនឹង គាត់អាចបំភ្លឺពីហេតុការណ៍អ្វីដែលកើតឡើងនៅទួលពោធិ៍ជ្រៃ អ្វីដែលគាត់បានដឹងដែលថា អ្នកណាដែលជាអ្នកសម្ដែង ដែលអ្នកផ្ដល់សម្ភាសនៅក្នុងខ្សែភាពយន្តនោះក៏គាត់អាចបញ្ជាក់បានដែរ។

[០៩:១៤:០៤]

ដូច្នេះការជំទាស់របស់គាត់នោះដែលថា ជំទាស់ទៅនឹងសំណើរបស់យើងនោះគឺថា ជាការមិនស័ក្ដិសមទេ។ ប៉ុន្តែយើងសូមជម្រាបអង្គជំនុំជម្រះថា សំណើឯកសាររបស់យើងគឺឯកសារ E291 បាទ សូមកោះសាក្សីពីរឿងទួលពោធិ៍ជ្រៃគឺថ្ងៃទី១៧ មិថុនា ឆ្នាំ២០១៣។ នៅក្នុងសំណើនោះយើងបានស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីម្នាក់ ដែលនៅក្នុងនោះដែលសហព្រះរាជអាជ្ញាបានសួរហើយ គឺ

TCW-664។ សូមឱ្យកោះហៅសាក្សីនេះមកបំភ្លឺ ហើយសំណើដដែលនេះគឺ E291 ហើយនិងស្នើសុំឱ្យកោះហៅសាក្សីមួយទៀតគឺ 102 និង103។ នៅក្នុងទឡ្ហីករណ៍របស់យើងខ្ញុំហ្នឹង គឺថា សូមឱ្យសាក្សីពាក់ព័ន្ធទាំងអស់ដែលបញ្ជាក់នៅក្នុងដីកាដំណោះស្រាយ ទាក់ទងទៅនឹងទួលពោធិ៍ជ្រៃហ្នឹង គឺគប្បីតែកោះអញ្ជើញមកទាំងអស់ ដោយអង្គជំនុំជម្រះ។ ហើយយើងបានកត់សម្គាល់ឃើញថា យើងមិនមានការជំទាស់ទៅនឹងការកោះហៅ TCW-644 នោះទេ។ អ៊ីចឹងហើយយើងខ្ញុំសូមស្នើកោះហៅ ឱ្យអង្គជំនុំជម្រះកោះហៅសាក្សីទាំងពីរនេះ។

ទាក់ទងទៅនឹងសាក្សីថ្មីៗមិនទាន់មាន TCW ទេ គឺបុគ្គលម្នាក់ដែលបានមកពីបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣ និង០០៤នោះ យើងដឹងថា គាត់បាននិយាយអំពីទួលពោធិ៍ជ្រៃ គាត់និយាយពីទួលពោធិ៍ជ្រៃនោះក៏ដោយ ក៏ប៉ុន្តែមិនគួរឱ្យជឿជាក់នៅក្នុងដំណាក់កាលនេះទេ ទាក់ទងទៅនឹងអង្គហេតុ ពីព្រោះថា មិនដឹងថាជាសក្ខីកម្មរបស់គាត់ ឬអង្គហេតុដែលគាត់ដឹងផ្ទាល់ថា គាត់អាចបានដឹងបានឮ ដែរឬទេ? យើងមិនដឹងច្បាស់បែបនោះទេ។

[០៩:១៦:២៨]

ហើយពង្រីកអំពីមូលហេតុអំពីការបន្ថែមសាក្សីថ្មីៗបែបនេះ តាមពិតជាគោលការណ៍ យើងមិនមានបញ្ហាអ្វីក្នុងការកោះអញ្ជើញសាក្សីនេះទេ។ ប៉ុន្តែយើងយល់ថា ហេតុការណ៍នៅទួលពោធិ៍ជ្រៃនោះ គឺគប្បីតែពិនិត្យពិចារណាឱ្យបានលម្អិត ឱ្យបានខ្លាំង។ យើងមិនទាន់ឃើញមានភស្តុតាងណាដែលលើសលប់ពីសហព្រះរាជអាជ្ញាដែលឱ្យជឿជាក់បាននោះទេ។ ជាពិសេសទំនាក់ទំនងទៅរឿងការកាប់សម្លាប់ ហើយនិងទំនាក់ទំនងទៅនឹងការធ្វើសេចក្តីសម្រេច ការអនុវត្តនយោបាយនោះទេ។

យើងកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបាននិយាយនៅក្នុងសំណើនោះថា ខ្លួនមានបញ្ហាទាំងបញ្ហាថា និងភស្តុតាងរបស់ខ្លួនថាមិនគ្រាប់គ្រាន់ យើងយល់ស្របជាមួយគំនិតនេះ។ ហើយដើម្បីមានឱ្យមានពន្លឺការបំភ្លឺបន្ថែមទាក់ទងទៅនឹងកាលៈទេសៈ និងហេតុការណ៍នៅទីនោះ ទាល់តែកោះសាក្សីបន្ថែម។ យើងសូមបញ្ជាក់ទៀតថា ហើយសំណើរបស់យើងពីសប្តាហ៍មុននោះ គឺអំពីសារៈសំខាន់នោះគឺថា កោះហៅសាក្សី TCW-382 ដែលគាត់បាននិយាយបញ្ជាក់អំពីហេតុការណ៍នៅទួលពោធិ៍ជ្រៃ ដែលគាត់ឃើញនៅក្នុងខ្សែភាពយន្តនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

សូមអញ្ជើញលោកមេធាវី!

[០៩:១៨:០២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ ខ្ញុំនឹងនិយាយដោយខ្លីទេ ពាក់ព័ន្ធទៅនឹងចំណុចនេះ។

កាលពីកិច្ចប្រជុំរៀបចំសវនាការចុងក្រោយនោះ យើងបានបញ្ជាក់រួចមកហើយ ថាជាគោល-ការណ៍ យើងទុកឲ្យអង្គជំនុំជម្រះជាអ្នកវាយតម្លៃទៅលើឱកាសក្នុងការកោះហៅសាក្សីថ្មី។ យើងកត់សម្គាល់ឃើញថា សាក្សីបានមកផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃរួចមកហើយ។ ហើយអ្វីដែលសាក្សីបានលើកឡើងនោះ មិនទាន់គ្រប់គ្រាន់ទេ ហើយសហព្រះរាជអាជ្ញាបានសុំស្នើសុំបន្ថែម ស្នើសុំសាក្សីបន្ថែម។ ដូច្នេះខ្ញុំគិតថា មិនគួរណាស្នើសុំបែបនេះទៀត ដោយគួរតែបញ្ចប់ត្រឹមហ្នឹងទៅ។ អានេះហើយជាការលើកឡើងជូនអង្គជំនុំជម្រះ។

ជាថ្មីម្ដងទៀត ប្រសិនបើជាភស្តុតាងមិនគ្រប់គ្រាន់នោះ យើងគ្រាន់តែទាញសេចក្ដីសន្និដ្ឋានទៅដែលថាមិនមានព័ត៌មានគ្រប់គ្រាន់ តែប៉ុណ្ណឹងទៅបានហើយ ដូចជាមិនចាំបាច់កោះហៅសាក្សីបន្ថែមនោះទេ។ សូមអរគុណ នេះជាការកត់សម្គាល់របស់ខ្ញុំទៅលើសំណើរបស់សហព្រះរាជអាជ្ញា។

[០៩:១៩:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយសង្ខេបទាក់ទងទៅនឹងការបញ្ជាក់ដោយសង្ខេបរបស់មេធាវីការពារក្ដីទាំងពីរក្រុមដែរ។

ខ្ញុំសូមអនុញ្ញាតដើម្បីចាប់ផ្ដើមទៅនឹងមេធាវីការពារក្ដីរបស់លោក ខៀវ សំផន។ ជំហររបស់សហព្រះរាជអាជ្ញានោះ គឺពិតនោះ គឺថាមិននិយាយអំពីភស្តុតាងមិនគ្រប់គ្រាន់នោះទេ។ ប៉ុន្តែយើងនិយាយនៅក្នុងសំណើរបស់យើង តុលាការបានស្ដាប់សាក្សីមួយចំនួនច្រើនហើយ ទាក់ទងទៅនឹង ដែលថាជាជំហានដំបូង ដំណាក់កាលដំបូងនៃហេតុការណ៍ទួលពោធិ៍ជ្រៃ ហើយនិងការប្រមូលផ្ដុំមន្ត្រី ហើយ

និងទាហាន លន់ នល់ នៅក្នុងខេត្តពោធិ៍សាត់ និងប្រជុំ -- សាលប្រជុំពោធិ៍សាត់។ ហើយយើងបានស្តាប់ដឹងអំពីការដឹកតាមឡានធំ ពីទីនោះទៅនឹងទួលពោធិ៍ជ្រៃ។ ហើយយើងជឿជាក់ថាអាចនឹងមានសារប្រយោជន៍ដល់អង្គជំនុំជម្រះ ដើម្បីស្តាប់សាក្សីពីររូបទៀត ដែលស្ថិតនៅកន្លែងសម្លាប់មនុស្សនោះ ដែលថាម្នាក់គឺអ្នកភូមិបានមកនៅថ្ងៃបន្ទាប់ ហើយបានឃើញសាកសព ហើយគាត់បានរៀបរាប់ពីកន្លែងកើតហេតុ។

[០៩:២០:៤៥]

ហើយលទ្ធភាពទី២ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី០០៤ ដែលបានបញ្ជាក់ ហើយពេលខ្លះយើងមានការលំបាកក្នុងការបកស្រាយនៅក្នុងការអង្គហេតុដែលគាត់និយាយ។ ពីព្រោះយើងមើលឃើញតែសេចក្តីសង្ខេបនៃពាក្យសុំរបស់គាត់តែប៉ុណ្ណោះ។ ប៉ុន្តែផ្អែកលើពាក្យសុំរបស់គាត់នោះ គឺគាត់ជាបុគ្គល ជាទាហានដែលគាត់បានទៅដល់ទីកន្លែងសម្លាប់មនុស្សនោះ។

ខាងសហព្រះរាជអាជ្ញាមានជំហរបែបនេះ ប៉ុន្តែមេធាវីការពារក្តីនៅតែបន្តនិយាយថា គាត់មានសាក្សីបន្ថែមទៀតដែលបានឃើញ សាក្សីផ្សេងទៀតនៅកន្លែងសម្លាប់នោះ គឺជាសារប្រយោជន៍គួរតែស្តាប់អ្នកទាំងអស់នោះ។ ដូច្នេះអ្វីដែលសហព្រះរាជអាជ្ញាស្នើ គឺមូលដ្ឋានសំខាន់បែបនេះ។

ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តីរបស់លោក នួន ជា ទៅ TCW-382 នោះ ហើយខ្ញុំមិនយល់ថាសំណើនេះពាក់ព័ន្ធទេ ដោយសារថាគាត់ជាផលិតករនៃខ្សែភាពយន្ត។ ហើយផ្អែកទៅតាមអ៊ីម៉ែលដែលគាត់ផ្ញើពីសប្តាហ៍មុន ប៉ុន្តែយើងមិនឃើញមានអ្វីដែលគាត់ដឹងច្រើនអំពីហេតុការណ៍នោះទេ។ នៅក្នុងអ៊ីម៉ែលនោះ គឺថាគាត់មិនយល់ច្បាស់អំពីខ្សែភាពយន្តរបស់គាត់នោះទេ។ គាត់រិះគន់ថាបាទថាដែលគេផ្សាយតាមភ្នំពេញប៉ុស្តិ៍នោះ គឺថាមានខ្លឹមសារដែលមិនត្រឹមត្រូវ។ ប៉ុន្តែនេះហើយគឺជាមូលហេតុដែលយើងថាគាត់មិនយល់ច្បាស់ទេ។ ប៉ុន្តែអ្វីដែលយើងស្នើ គឺយើងស្នើយកអ្នកដែលបានឋិតនៅ --បានទៅដល់កន្លែងកើតហេតុនោះ។

[០៩:២២:៣៦]

ដូច្នេះហើយបើយើងប្រៀបធៀបទៅនឹងផលិតករភាពយន្តនោះ គឺមិនសមស្របទេ និយាយពីសាក្សីដែលយើងស្នើនោះ។ ហើយទាក់ទងទៅនឹងអ្វីដែលភាគីលើកឡើងផ្សេងទៀតនោះ ខ្ញុំមិនមានអ្វីឆ្លើយតបទៀតទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងហសព្រះរាជអាជ្ញា។ ហើយបញ្ហានេះអង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចក្នុងរយៈពេលខ្លីឆាប់ៗខាងមុននេះ។

ហើយជាបន្តទៅនេះ បញ្ហាមួយទៀតនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញ លើសេចក្ដីសម្រេចមិនកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស សារិន។

[០៩:២៣:១៥]

ទោះបីវិធានផ្ទៃក្នុងមិនបានចែងអំពីការពិចារណាឡើងវិញទៅលើសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការពិចារណាទៅសំណើពាក់ព័ន្ធនឹងបញ្ហា ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនោះទេ។ ទោះបីជាយ៉ាងនេះក្ដីសហព្រះរាជអាជ្ញា -- សហមេធាវីនាំមុខបានធ្វើសំណើជាបឋមមកអង្គជំនុំជម្រះថា ខ្លួនមានបំណងចង់បញ្ចេញមតិយោបល់លើសំណើនេះ។ សហមេធាវីនាំមុខនឹងទទួលបានពេលវេលាចំនួន២០នាទី ហើយក្រុមមេធាវីការពារក្ដីនីមួយៗទទួលបានពេលវេលា១០នាទី ប្រសិនបើមេធាវីមានបំណងចង់ធ្វើការឆ្លើយតប។

តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសនៅក្នុងការដែលសម្រេចនូវបំណងរបស់ខ្លួន ខ្លួនដែលចង់បញ្ចេញនូវមតិយោបល់លើសំណើរបស់សហព្រះរាជអាជ្ញាចំពោះករណីពិចារណាឡើងវិញ ក្នុងការកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន មកស្ដាប់សក្ខីកម្មនេះ។

[០៩:២៤:២១]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ លោក វ៉ែន ពៅ នឹងលើកយោបល់មួយចំនួន ហើយនិងត្រូវបន្តដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត សូមលោកប្រធានអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញ!

**លោក វ៉ែន ពៅ៖**

ជាបឋមខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពតំណាងសហព្រះរាជអាជ្ញា និងអង្គសវនាការទាំងមូល។

[០៩:២៤:៥៣]

ឆ្លើយតបទៅនឹងសំណើដែលបានលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ដែលស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញ លើសេចក្ដីសម្រេចទាក់ទងនឹងការបដិសេធលើសំណើសុំឲ្យកោះហៅកូនក្ដីរបស់ខ្ញុំបាទជាដើមបណ្ដឹងរដ្ឋប្បវេណី គឺលោក ស សារិន ជាថ្មីឡើងវិញនេះ។ ក្នុងនាមខ្ញុំបាទជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ ខ្ញុំសូមយល់ស្រប និងគាំទ្រចំពោះសំណើនេះតែក្នុងន័យការកោះហៅគាត់ក្នុងៗរបៀបដោយសន្តិវិធី និងក្នុងនាមគាត់ជាមេធាវីដើម -- ជាដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។

ដោយឡែកចំពោះការស្នើសុំរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងថា បើដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបដិសេធមិនព្រមផ្ដល់សក្ខីកម្ម គឺសុំឲ្យដាក់ទណ្ឌកម្មស្របតាមវិធាន៣៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នោះគឺភាគីយើងខ្ញុំសូមបដិសេធ និងសូមមិនយល់ស្របនឹងសំណើនេះទេ។ ព្រោះថាការដែលព្រះរាជអាជ្ញាបានលើកឡើងក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នេះពុំសមហេតុផល និងត្រឹមត្រូវឡើយ ព្រោះថាកូនក្ដីខ្ញុំបានពុំបានរំលោភលើវិធាន៣៥ នៃវិធាននេះឡើយ។

[០៩:២៦:១៥]

សូមជម្រាបអង្គសវនាការថាកូនក្ដីខ្ញុំបាទ ស សារិន តុលាការបានទទួលស្គាល់គាត់ក្នុងនាម និងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងក្ដី០០២។ គាត់ត្រូវបានតុលាការកោះហៅគាត់ និងស្ដាប់សក្ខីកម្មរបស់គាត់ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី គឺបានន័យថាគាត់ជាភាគីមួយក្នុងដំណើរការនីតិវិធីនៃរឿងក្ដីនេះ។ ជាពិសេសយោងតាមវិធាន២៣ ចំណុច៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានចែងយ៉ាងច្បាស់ថា ខ្ញុំសូមអនុញ្ញាតអានចំណុចទី៤ នេះលោកប្រធាន "ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានសាកសួរដូចសាក្សីធម្មតាក្នុងរឿងក្ដីមួយនេះបានទេ"។

បញ្ហាមួយទៀត ខ្ញុំសូមបញ្ជាក់ជូនអង្គសវនាការផងដែរថា បញ្ហាដែលកូនក្ដីខ្ញុំបាទបដិសេធមិនព្រមផ្ដល់សក្ខីកម្ម គឺគាត់បានបញ្ជាក់យ៉ាងច្បាស់រួចហើយកាលពីសវនាការថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ កន្លងមកនេះ។ បញ្ហាសំខាន់គឺពាក់ព័ន្ធទៅនឹងបញ្ហាភ័យខ្លាចអំពីសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន

របស់គាត់ ក៏ដូចជាក្រុមគ្រួសាររបស់គាត់ផ្ទាល់ ដែលគាត់មានការបារម្ភនៅពេលដែលគាត់ត្រឡប់ទៅលំនៅដ្ឋានវិញក្រោយពេលផ្ដល់សក្ខីកម្មរួច។ ហើយការស្នើសំណើទាំងនេះ តុលាការបានសម្រេចសេចក្ដីរួចហើយនៅថ្ងៃសវនាការទី២៩ ខែមេសា ២០១៣ កន្លងមកនេះហើយដែរ។

[០៩:២៧:៥៥]

ជាពិសេសតាមរយៈអនុស្សរណៈរបស់អង្គជំនុំជម្រះនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ ក៏បានបញ្ជាក់រួចហើយដែរថា បញ្ហានេះយ៉ាងច្បាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានបង្ខំឲ្យផ្ដល់សក្ខីកម្មបានឡើយ ដោយអនុលោមតាមក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក វិធាន២៣ចំណុច៤ នៃវិធានផ្ទៃក្នុង។

ចំណុចមួយទៀត ពាក់ព័ន្ធនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញអំពីឋានៈរបស់គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ។ យើងខ្ញុំយល់ថាការលើកឡើងនេះពុំសមហេតុផលទេ និងយើងខ្ញុំសូមបដិសេធ និងជំទាស់ចំពោះសំណើនេះ។ ដោយហេតុថាកូនក្ដីខ្ញុំ គាត់នៅតែមានបំណង និងឆន្ទៈចូលរួមក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីដដែល។ ហើយមូលហេតុចម្បងដែលគាត់បដិសេធមិនព្រមផ្ដល់សក្ខីកម្មនេះ គឺមានហេតុផលច្បាស់លាស់ដែលពាក់ព័ន្ធពីបញ្ហាសុវត្ថិភាពសុវត្ថិភាពផ្ទាល់ខ្លួនគាត់ក៏ដូចជាក្រុមគ្រួសារគាត់។

[០៩:២៩:០២]

ជាក់ស្ដែងនៅថ្ងៃសវនាការថ្ងៃទី២៩ ខែមេសា ២០១៣ គាត់បានបញ្ជាក់យ៉ាងច្បាស់ បានលើកឡើងជាឧទាហរណ៍ជាក់ស្ដែងករណីឃាតកម្មមួយ ដែលបានកើតឡើងលើរូបលោក ហាំង ង៉ោ ជាតួឯកក្នុងភាពយន្តឯកសាររឿងវាលពិឃាត *"ឃីលលីងហ្វៀល"* ដ៏ល្បីល្បាញត្រូវបានគេលួចធ្វើឃាតនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៦។

សូមជម្រាបអង្គសវនាការថា តាមសម្ដីរបស់ ឌុច ដែលបានញ្ជាក់ក្នុងកំណត់ហេតុលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីថ្ងៃទី២៥ ខែវិច្ឆិកា ២០០៩ បានបញ្ជាក់យ៉ាងច្បាស់ហើយ គឺក្នុងករណីសំណុំរឿង០០១។ ខ្ញុំសូម -- ដែលមានលេខឯកសារគឺ E3/80.1 ដែលមាន ERN ជាភាសាខ្មែរ 00406939, ERN ជាភាសាអង់គ្លេស 00406703 និង ERN ជាភាសាបារាំង 00406833។ ក្នុងនោះគាត់បានបញ្ជាក់ផងដែរថា "ម្យ៉ាងទៀត ខ្ញុំនៅតែយល់ថា ប៉ុល ពត បានប្រើល្បិចសម្លាប់ ដែលស្ដាលីនបានប្រើសម្លាប់ ត្រុតស្គី ដើម្បីសម្លាប់ ហាំង ង៉ោ និងសម្លាប់ប្រពន្ធខ្ញុំ"។

[០៩:៣០:២៣]

ហេតុនេះហើយកូនក្តីខ្ញុំ ក៏គាត់មានការភ័យបារម្ភពីករណីគាត់ដូចនឹងករណី ហាំង ង៉ោ នេះដែរ។ ម្យ៉ាងវិញទៀត សំណើរបស់កូនក្តីរបស់ខ្ញុំបាទ ក៏បានស្នើសុំទៅអង្គជំនុំជម្រះរួចហើយកាលពីសវនាការ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ កន្លងមកនេះ។ ហើយសំណើនេះគាត់ក៏ត្រូវបានតុលាការសម្រេចបដិសេធរួចហើយដែរ។

ហេតុនេះយើងខ្ញុំយល់ថា ក្នុងករណីបើអង្គជំនុំជម្រះកោះហៅគាត់ គឺសុំឲ្យកោះហៅគាត់ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីតាមសន្តិវិធី ដោយគ្មានការបង្ខិតបង្ខំដល់រូបគាត់ឡើយ។ បើអាចធ្វើទៅរួចអង្គជំនុំជម្រះគួរចាត់វិធានការការពារសមស្របណាមួយដែលអាចរក្សាសុវត្ថិភាព និងសន្តិសុខដល់គាត់ជាការប្រសើរ។

ខ្ញុំសូមផ្ទេរវេទិកាជូនសហភាតារបស់ខ្ញុំដើម្បីធ្វើការកត់សម្គាល់បន្ត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញ!

[០៩:៣១:៤៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំសូមអរគុណដែលបានផ្តល់ឱកាសឲ្យយើងខ្ញុំនិយាយបន្ថែមទៅលើសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ស សារិន។

យើងក៏ចង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះផ្តល់ភស្តុតាង ដូចជាអ្នកដទៃទៀតនៅក្នុងសវនាការនេះ។ ហើយសហភាតារបស់ខ្ញុំទើបតែបានលើកឡើងហើយ អំពីកង្វល់ និងការព្រួយបារម្ភរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះពាក់ព័ន្ធទៅនឹងសិទ្ធិរបស់គាត់។ ដូច្នេះ ខ្ញុំចង់លើកឡើងដើម្បីបញ្ជាក់អំពីសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងអំពីទឡ្ហីករណ៍ផ្លូវច្បាប់មួយចំនួន ដែលដូចជាមិនមានមូលដ្ឋាន។ ហើយអង្គជំនុំជម្រះនឹងកំណត់ -- បានកំណត់ពាក់ព័ន្ធទៅនឹងឋានៈ និងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួមកហើយ។

[០៩:៣២:៥៣]

ហេតុដូច្នេះហើយ ដែលខ្ញុំអាចលើកឡើងថាទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា គឺមិនមានមូលដ្ឋាន ហើយមិនអាចឲ្យជាមូលដ្ឋានសម្រាប់ការពិចារណានោះទេ។ មានចំណុចពីរចាំបាច់សំខាន់នៅ

ក្នុងសំណើរបស់សហព្រះរាជអាជ្ញា។ ចំណុចទី១ គឺជាការបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីដូចទៅនឹងសាក្សីនៅពេលដែលមកផ្តល់សក្ខីកម្ម។ ចំណុចទី២ ដែលសំខាន់ដែរនោះ ដែលជាសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា គឺគាត់ថាអង្គជំនុំជម្រះអាចដាក់ទណ្ឌកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនោះបាន ដោយធ្វើឱ្យគាត់បាត់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះខ្ញុំនឹងលើកឡើងពាក់ព័ន្ធទៅនឹងចំណុចទាំងពីរនេះ។

ឥឡូវនេះខ្ញុំនិយាយពាក់ព័ន្ធទៅនឹងការប្រដូចដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសាក្សី ដែលនិយាយអំពីកាតព្វកិច្ចរបស់ពួកគាត់នៅពេលដែលអង្គជំនុំជម្រះកោះហៅ។ ខ្ញុំមានការសោកស្តាយណាស់ដែលថាអស់រយៈពេល២ឆ្នាំមកហើយ ដែលខ្ញុំព្យាយាមពន្យល់ថាដើមបណ្តឹងរដ្ឋប្បវេណីគាត់ខុសគ្នាពីសាក្សី។ ហើយខ្ញុំ ឥឡូវនេះខ្ញុំនឹងបញ្ជាក់ម្តងទៀតថា វិធានដែលលើកឡើងដោយសហព្រះរាជអាជ្ញានោះ គឺជាវិធានដែលបកស្រាយផ្ទុយទៅនឹងអ្វីដែលបានលើកឡើង។ ហើយខ្ញុំនឹងព្យាយាមបង្ហាញពីករណីនេះ។

[០៩:៣៤:១៣]

ជាដំបូងគេលើកឡើងថា សហព្រះរាជអាជ្ញាអាចបង្ខំឱ្យដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្ម។ ហើយគេលើកឡើងអំពីវិធាន៤១នៃវិធានផ្ទៃក្នុងដែលមានចំណងជើងជាភាសាបារាំងថា"ការកោះហៅ"។ ខ្ញុំជឿថា ប្រសិនបើយើងចង់វិភាគទៅលើវិធាននេះ យើងត្រូវតែពិនិត្យមើលវិធានជាភាសាបារាំងពីព្រោះថាវាទាញចេញមកពីច្បាប់ស៊ីវិលឡូ ហើយយើងត្រូវតែពិនិត្យមើលខ្លឹមសារជាភាសាបារាំង។ ជាភាសាបារាំងពាក្យថា "កោះហៅ" នេះមិនមានន័យថាជាកាតព្វកិច្ចទេ មិនមែនន័យថាជាការបង្ខំទេ។ ហើយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំងនោះ នៅពេលដែលមានការបង្ខំ គឺថាត្រូវតែមានវិធានជាក់លាក់ ដែលដាក់ទណ្ឌកម្មទៅលើអ្នកដែលគេកោះហៅហើយមិនឆ្លើយតប មិនឆ្លើយ។ វាមិនត្រឹមត្រូវ -- ចំពោះដើមបណ្តឹងរដ្ឋប្បវេណីយើងមិនអាចធ្វើអ៊ីចឹងបានទេ។

ចំណុចមួយទៀតគឺខ្ញុំលើកឡើង ខ្ញុំសំដៅទៅដល់ភាសាបារាំងនោះពាក្យថា "កោះហៅ" នេះមិនមែនមានន័យថា ជាការបង្ខំ ឬជាកាតព្វកិច្ចនោះទេ។

[០៩:៣៥:២៥]

ខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងកថាខណ្ឌ៧ នៃជើងទំព័រ១៦។ គាត់លើកឡើងអំពីវិធាន៩០ ដែលគាត់បានលើកឡើងថា "ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែឆ្លើយតបទៅនឹងការកោះហៅរបស់អង្គជំនុំជម្រះ"។ ខ្ញុំអានវិធាន៩០ ជាច្រើនលើកច្រើនសារួចមកហើយ ខ្ញុំដូចជាមិនឃើញមានបទប្បញ្ញត្តិណាមួយដែលនិយាយបែបនេះនោះទេ។

ទទ្បីករណ៍ទី២ របស់សហព្រះរាជអាជ្ញា គឺជាការយោងទៅលើប្រភពច្បាប់ ជាពិសេសទៅលើច្បាប់បារាំង គឺជើងទំព័រលេខ២៣ នៃឯកសាររបស់ខ្លួនដែលមាននៅក្នុងកថាខណ្ឌ៨។ នៅក្នុងជើងទំព័រ ២៣ នេះសហព្រះរាជអាជ្ញាបានលើកឡើងនូវក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣១២។ ខ្ញុំឃើញថាមាត្រានេះដូចជាអត់មានរឹតត្បិតទៅលើដើមបណ្តឹងរដ្ឋប្បវេណីទេ គ្រាន់តែចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីអាចឆ្លើយសំណួរទៅនឹងជនជាប់ចោទ ដូចជាភាគីផ្សេងដែរ"។ ដូច្នេះ ខ្ញុំមើលទៅដូចជាមិនឃើញមានលក្ខណៈបង្ខំឲ្យមកផ្តល់សក្ខីកម្មនោះទេ។

[០៩:៣៦:៤៥]

ចំពោះជើងទំព័រលេខ២៣ នេះដែរ ក៏បានលើកឡើងនូវមាត្រា៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហើយក្នុងនោះគឺលើកឡើងនូវជើងទំព័រ២៣ ហើយនៅក្នុងនោះគឺលើកឡើងអំពីវិធាន៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងនោះ។ មាត្រានេះគឺនិយាយថា "ដើមបណ្តឹងរដ្ឋប្បវេណីមានលទ្ធភាពបញ្ចេញមតិយោបល់នៅចុងសវនាការនៅពេលបញ្ចប់ការពិភាក្សាដេញដោល"។ នេះគឺជាលទ្ធភាពមួយ។

ហើយនៅក្នុងជើងទំព័រ៤៦ នោះគឺថាយើងមាននិយាយអំពីយុត្តិសាស្ត្រ ដែលថាដែលបង្ហាញពីលទ្ធភាព និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ សិទ្ធិនេះគឺវាមិនពាក់ព័ន្ធទៅដល់សិទ្ធិរបស់ជនជាប់ចោទនោះទេ។

ហើយនៅក្នុងជើងទំព័រលេខ២៣ ហើយនិងយោងតាមមាត្រា៣៤៦ នោះការលើកឡើងនោះគួរតែលើកឡើងអំពីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៣២៩។ មាត្រា៣២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងនោះចែងអំពីតែសាក្សីទេ គឺមិននិយាយអំពីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

[០៩:៣៨:២០]

ចំណុចទី៣ ពាក់ព័ន្ធទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺជើងទំព័រ៣១ ដែលគាត់លើកថា "ដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាសាក្សីដែរ មានសិទ្ធិក្នុងការនៅស្ងៀម នៅពេលដែលមានការដាក់បន្ទុកមកលើខ្លួន មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។ ដូច្នេះក្នុងនេះមាននិយាយតែអំពីវិធាន២៨ នៃវិធានផ្ទៃក្នុងដែលនិយាយតែអំពីសាក្សីទេ មិនមានការនិយាយសំដៅដល់ដើមបណ្តឹង រដ្ឋប្បវេណីនោះទេ។ ដូច្នេះមានតែកាតព្វកិច្ចជាក់លាក់របស់សាក្សីតែប៉ុណ្ណោះ។

ហើយកថាខណ្ឌ១៤ នៃសំណើរបស់សហព្រះរាជអាជ្ញា គឺពាក់ព័ន្ធទៅនឹងសក្ខីកម្មនេះដដែល គឺពាក់ព័ន្ធទៅនឹងឆ្លើយដាក់បន្ទុករបស់ខ្លួន គឺថាដើមបណ្តឹងរដ្ឋប្បវេណីអាចនៅស្ងៀម។

ហើយជើងទំព័រ៤៦, ៤៨ និយាយអំពីវិធាន២៨ដដែល ដែលវិធាននេះមិននិយាយសំដៅទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

[០៩:៣៩:២៤]

ចំណុចចុងក្រោយនៃទឡ្ហីករណ៍របស់ព្រះរាជអាជ្ញា គឺកថាខណ្ឌ១៦។ សហព្រះរាជអាជ្ញាបានលើកឡើងថា "នៅពេលដែលយើងនៅស្ងៀមមិនឆ្លើយតប ហើយនិងការបដិសេធមិនព្រមមកផ្ដល់សក្ខីកម្មនោះ ដើមបណ្ដឹងរដ្ឋប្បវេណីគឺអាចចាត់ទុកថា ជាអ្នកដែលជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ"។ យុត្តិសាស្ត្រដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១៦ នេះជាយុត្តិសាស្ត្រដែលពាក់ព័ន្ធទៅនឹងសាក្សីនៅក្នុងនីតិវិធីអន្តរជាតិ។ វាមិនមានលក្ខណៈជាក់លាក់ពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ដូច្នេះយុត្តិសាស្ត្រទាំងអស់នេះមិនអាចអនុវត្តចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីរបស់យើងនេះទេ។

ដើម្បីសន្និដ្ឋានពាក់ព័ន្ធទៅនឹងចំណុចទី១នេះ ខ្ញុំសូមរំឭកថានៅពេលដែលយើងលើកឡើងអំពីប្រភពច្បាប់នោះ ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង គឺដាក់ទណ្ឌកម្មចំពោះបុគ្គលមួយចំនួនដែលមិនឆ្លើយតបទៅនឹងការកោះហៅរបស់អង្គជំនុំជម្រះ។ គឺសំដៅតែទៅលើសាក្សីទេ គឺមាត្រា៤៣៧, ៤៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺចែងតែអំពីសាក្សីនោះទេ។ ចំពោះក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរដែលអង្គជំនុំជម្រះយោងនោះ យើងត្រូវអានមាត្រា១៣៣ -- សូមទោស ១៥៣ គឺនិយាយតែអំពីសាក្សីទេ។ ក្នុងករណីដែលសាក្សីមិនព្រមឆ្លើយតបទៅនឹងការកោះហៅរបស់ចៅក្រមស៊ើបអង្កេត ឬមួយក៏យើងអាចយោងទៅលើមាត្រា៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលដាក់ទណ្ឌកម្មតែទៅលើសាក្សីតែប៉ុណ្ណោះ ចំពោះសាក្សីណាដែលមិនព្រមឆ្លើយតបទៅនឹងការកោះហៅរបស់អង្គជំនុំជម្រះ។

[០៩:៤១:១៩]

ខ្ញុំសូមបញ្ជាក់ថា មាត្រា១១៥នេះ និយាយតែសាក្សី ហើយមានមាត្រាបីទៀតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលលើកឡើងអំពីដើមបណ្ដឹងរដ្ឋប្បវេណី ដោយមិនមានបានចែងថាមានលទ្ធភាពក្នុងការដាក់ទណ្ឌកម្មទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើគាត់មិនផ្ដល់ មិនមកផ្ដល់សក្ខីកម្មនោះទេ។

ឥឡូវនេះ ខ្ញុំចូលទៅដល់ចំណុចទី២ របស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឲ្យដាក់ទណ្ឌកម្មដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីបដិសេធមិនព្រមមកផ្ដល់សក្ខីកម្ម។ ដោយពន្យល់ថា អង្គជំនុំជម្រះមានលទ្ធភាពក្នុងការដកនូវសិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយចាត់ទុកជា

សាក្សីវិញ។ ដើម្បីធ្វើយុត្តកម្មទៅលើទឡ្ហីករណ៍នេះ គឺសហព្រះរាជអាជ្ញាបានយោងទៅលើ បានបញ្ជាក់នៅក្នុងកំណត់ជើងទំព័រ៦៩ ដែលនិយាយអំពីវិធាន២៣ស្ទួន(៥) នៃវិធានផ្ទៃក្នុង។ វិធាន២៣ស្ទួន(៥) នៃវិធានផ្ទៃក្នុងបានពន្យល់យ៉ាងច្បាស់ថា "ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការសម្រេចនៅពេលណាមួយ នៅដំណាក់កាលមុនជំនុំជម្រះក្នុងការលះបង់សិទ្ធិរបស់ខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី"។

[០៩:៤២:៤៦]

ដូច្នេះ ខ្ញុំចោទសួរថាតើយើងអាចទាញនូវលទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការគិតថា នេះជាទណ្ឌកម្មយ៉ាងម៉េចកើត? ទណ្ឌកម្មត្រូវតែមានជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងវិធានផ្ទៃក្នុងគឺមិនមានចែងជាលាយលក្ខណ៍អក្សរអំពីការដាក់ទណ្ឌកម្មនេះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចដាក់ទណ្ឌកម្មទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានឡើយ។

ដើម្បីសន្និដ្ឋានជាថ្មីម្ដងទៀត ខ្ញុំសោកស្ដាយណាស់ក្នុងការលើកឡើងបែបនេះ ក៏ប៉ុន្តែខ្ញុំគិតថាវាជាការសំខាន់ណាស់ ដែលអង្គជំនុំជម្រះត្រូវតែពិចារណាទៅលើសិទ្ធិ និងឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ យើងមិនអាចនិយាយថា ដើមបណ្ដឹងរដ្ឋប្បវេណីដូចជាសាក្សី ហើយយើងអាចដាក់ទណ្ឌកម្មដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

ដូច្នេះ ខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះទាត់ចោលនូវទឡ្ហីករណ៍គតិយុត្តរបស់សហព្រះរាជអាជ្ញា ដូចអ្វីដែលខ្ញុំបានលើកឡើង។ ហើយសូមឲ្យអង្គជំនុំជម្រះចាត់ទុកថា ទឡ្ហីករណ៍ទាំងអស់នេះមិនអាចជាមូលដ្ឋានឲ្យអង្គជំនុំជម្រះកែប្រែសេចក្ដីសម្រេចរបស់ខ្លួនទៅលើប្រធានបទនេះបានឡើយ។ សូមអរគុណលោកប្រធាន។

[០៩:៤៤:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តអង្គជំនុំជម្រះផ្ដល់ឱកាសជូនទៅក្រុមមេធាវីការពារក្ដី ប្រសិនបើក្រុមមេធាវីការពារក្ដីមានបំណងឆ្លើយតបទៅលើបញ្ហានេះ។

មន្ត្រីរដ្ឋបាលតុលាការមើលបញ្ហាបច្ចេកទេសនៃការបកប្រែភាសា ដូចជាមានការឆ្លងភាសា។

**អ្នកបកប្រែ៖**

សូមគោរពលោកប្រធាន ដំណើរការល្អឡើងវិញហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទសូមអរគុណ។

[០៩:៤៥:៥៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះអ្វីៗប្រសើរវិញហើយលោកប្រធាន។ គឺថាខ្ញុំសូមឆ្លើយតបដោយសង្ខេបចំពោះខាងព្រះរាជអាជ្ញា ព្រោះថាព្រះរាជអាជ្ញាគាត់បានលើកឡើងអំពីការពិចារណាផ្នែកអង្គច្បាប់។ ហើយបានលើកឡើងថាជាការត្រឹមត្រូវដែលអង្គបុរេបានរកឃើញថា វាមានការពិចារណារួចហើយនៅក្នុងករណីបី។ ទី១ គឺនៅពេលដែលមានការផ្លាស់ប្តូរកាលៈទេសៈអនុញ្ញាត។ ទី២ នៅពេលដែលតុលាការរកឃើញថា ការសម្រេចហ្នឹងគឺវាមានបញ្ហាកំហុស និងទី៣គឺនៅពេលដែលមានផលប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។

ខ្ញុំបានអានពីមុនរួចមកហើយថា វាមិនមានការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈណាមួយឡើយ។ ដូច្នេះ ខ្ញុំគិតថាវាគ្មានហេតុផលណាមួយ ឬក៏គ្មានទឡ្ហីករណ៍ណាមួយជំទាស់ទៅលើសេចក្តីសម្រេចរបស់សាលាដំបូងនោះទេ។ ហើយសេចក្តីសម្រេចរបស់សាលាដំបូងក៏មិនមានបង្កឲ្យមានផលប៉ះពាល់ដល់យុត្តិធម៌ដែរ។ ដូច្នេះ វាមិនមានអ្វីដែលជំទាស់ទៅដល់ការសម្រេចរបស់សាលាដំបូងបាននោះទេ។

[០៩:៤៦:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី វ៉ិចទ័រ កូប៉េ។

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូលហើយលោក លោកស្រីចៅក្រមផង។

ខ្ញុំមានយោបល់ខ្លីឆ្លើយតបទៅនឹងសំណើរបស់តំណាងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការកោះហៅសាក្សី អ៊ំ!សូមទោស! ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ហើយនិងការលើកអំពីសំណើមួយចំនួនទាក់ទងទៅនឹងវិធានការអនុវត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[០៩:៤៦:៤៣]

ការឆ្លើយបញ្ជាក់របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ ខ្ញុំអាចទទួលយកបានមួយចំនួន ហើយមួយចំនួនទៀតដែលយើងឃើញថា មានចំណុចដែលយើងអាចលើកជូនអង្គជំនុំជម្រះ ដើម្បីធ្វើការវិនិច្ឆ័យ។

បញ្ហាទី១ ទាក់ទងទៅនឹងការកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន នេះមកជាថ្មីម្ដងទៀតតាមសំណើរបស់តំណាងសហព្រះរាជអាជ្ញានេះ។ យើងខ្ញុំយល់ឃើញថា ទោះបីជាក្នុងវិធានការដែលអង្គជំនុំជម្រះកោះហៅដោយគ្មានលក្ខណៈបង្ខំចំពោះលោក ស សារិន ក៏ដោយ វាមានចំណុចបង្ហាញអំពីការផ្ដុយទៅឆន្ទះរបស់លោក ស សារិន ដែលបានបញ្ជាក់យ៉ាងច្បាស់រួចហើយនៅក្នុងអង្គសវនាការនេះ ថាលោកនឹងមិនឆ្លើយបញ្ជាក់បំភ្លឺណាមួយទេ ក្នុងករណីដែលវិធានការការពារដែលគាត់ស្នើសុំនោះមិនត្រូវបានផ្ដល់ឲ្យ។ ដូច្នេះចំណុចនេះ បើសិនជាអង្គជំនុំជម្រះចេញដីកាដើម្បីកោះហៅលោក ស សារិន មកជាថ្មីម្ដងទៀត ក៏វាគ្មានប្រយោជន៍ដែរ ដោយសារតែលោក ស សារិន បានបង្ហាញឆន្ទះរបស់ខ្លួនហើយ។

[០៩:៤៨:០៦]

ទាក់ទងទៅនឹងឋានៈរបស់លោក ស សារិន ដែលតាមសំណើរបស់សហព្រះរាជអាជ្ញាថា សូមឲ្យប្ដូរមកជាសាក្សីវិញនោះ។ យើងខ្ញុំយល់ឃើញថា វិធានការនេះពុំសមស្របទេ ហើយការឆ្លើយបញ្ជាក់របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គឺមានលក្ខណៈដែលអាចទទួលយកបាន។ ដោយហេតុថាក្នុងរយៈពេល៦ឆ្នាំកន្លងមកនេះ ការតាំងពីចាប់ផ្ដើមនីតិវិធីរបស់តុលាការយើងនេះ លោក ស សារិន បានបង្ហាញខ្លួនគាត់ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី។ ក៏ប៉ុន្តែ ក្នុងដំណាក់កាលចុងក្រោយបំផុតតំណាងសហព្រះរាជអាជ្ញាបែរជាស្នើឲ្យលោក ស សារិន ធ្វើជាសាក្សី ដោយបង្ខំឲ្យគាត់មកឆ្លើយបំភ្លឺចំពោះមុខអង្គជំនុំជម្រះនេះ។ ពុំមានលក្ខណៈសមស្របទេ បើយើងពិនិត្យទៅលើផ្នត់គំនិតរបស់បុគ្គលជារួមវិញ។ ពីព្រោះលោក ស សារិន គាត់បានមកបង្ហាញខ្លួននៅក្នុងនីតិវិធីនៃសំណុំរឿង០០២/០១ នេះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងគោលបំណងដើម្បីបង្ហាញអំពីការខូចខាតរបស់គាត់ ដើម្បីទាមទារសំណងជារួម ឬក៏ការជួសជុលនូវផ្លូវចិត្តរបស់គាត់ ដែលចំណុចនេះផ្ទុយអំពីសាក្សីដែលមកបំភ្លឺមកចំពោះមុខអង្គជំនុំជម្រះ ដើម្បីផ្ដល់នូវអង្គហេតុ ឬក៏ភស្តុតាងផ្សេងៗជូនអង្គជំនុំជម្រះដើម្បីធ្វើការពិនិត្យ និងសម្រេច។

[០៩:៥០:០៦]

ដូច្នេះគោលបំណងរបស់លោក ស សារិន មិនអានត្រូវបានបង្ខំឲ្យផ្លាស់ប្តូរអំពីឋានៈរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះឡើយ។ ដូចមានចែងក្នុងវិធាន២៣ នៃវិធានផ្ទៃក្នុងដែលបញ្ជាក់អំពីបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនមានសិទ្ធិធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងឋានៈជាអ្នករងគ្រោះដែលប៉ះពាល់ដល់ -- មានការខូចខាតប៉ះពាល់ដល់រូបគាត់ផ្ទាល់ ឬក៏ប៉ះពាល់ដល់ផ្លូវចិត្តរបស់គាត់ជាដើម។

ដូច្នេះការផ្លាស់ប្តូរឋានៈ វាពុំមានលក្ខណៈសមស្របដើម្បីបង្ហាញនូវយុត្តិធម៌ឡើយ ដោយសារតែបុគ្គលម្នាក់ដែលបានបង្ហាញពីការខូចខាតរួចហើយនោះ មិនអាចបង្ហាញនូវផ្នត់គំនិតជាអ្នកផ្តល់នូវសក្ខីកម្មកណ្តាលសម្រាប់ផ្តល់ភស្តុតាងដល់អង្គជំនុំជម្រះទេ។

ចំណុចមួយទៀត ដែលតំណាងសហព្រះរាជអាជ្ញាប្រហែលជាយល់ច្រឡំអំពីការប្តូរឋានៈរបស់លោក ស៊ីវិន ហេដឌ័រ ក្នុងឋានៈជាសាក្សី ជាអ្នកជំនាញមកជាសាក្សី ហើយលក្ខខណ្ឌនៃការអនុវត្តចំពោះលោក ស សារិន នេះគឺមិនដូចគ្នាទេ។ ដោយសារការផ្លាស់ប្តូរឋានៈពីដើមបណ្តឹងរដ្ឋប្បវេណីមកជាសាក្សីវិញនេះ វាមានលក្ខណៈខុសគ្នាតាំងពីចំណុចចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃសវនាការ។ វាទាក់ទងទៅនឹងកម្មវត្ថុនៃឋានៈរបស់គាត់ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនេះ។

បាទសូមអរគុណ។

[០៩:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

អរគុណនូវមតិយោបល់របស់ភាគីដែលបានលើកឡើងពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយសូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

កុំអាលទាន់សហព្រះរាជអាជ្ញា! ព្រោះមានខាងមេធាវីនៅមានមតិយោបល់ផ្សេងទៀត។ សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

មានបញ្ហានៃប្រព័ន្ធបកប្រែភាសាទៀតហើយ លោកមន្ត្រីរដ្ឋបាលសម្របសម្រួលភ្លាម!

សូមអញ្ជើញលោកស្រីមេធាវី!

[០៩:៥៣:១០]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន ខ្ញុំនិយាយដោយខ្លីទេ។ ខ្ញុំគ្រាន់តែចង់ជម្រាបជូនថា ខាងការពារក្ដីលោក ខៀវ សំផន នេះមិនដែលធ្លាប់គាំទ្រអំណះអំណាងរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ដោយសារខ្ញុំគាំទ្រគាត់នោះ ដោយសារខ្ញុំមានការមានភាពខុសគ្នាយ៉ាងច្បាស់លាស់អំពីឋានៈដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងសាក្សី។

ខ្ញុំសូមរំឭកថា យើងបានដាក់សារណានៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ E267/1។ អ៊ីចឹងដើមបណ្ដឹងរដ្ឋប្បវេណីនេះមានឋានៈពិសេសនៅចំពោះមុខអង្គជំនុំជម្រះយើងនេះ។ ខ្ញុំឃើញថាគួរឲ្យភ្ញាក់ផ្អើលណាស់ សហព្រះរាជអាជ្ញាបានសុំឲ្យការពារដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ហើយឥឡូវនេះខាងដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញហើយថាគាត់មិនចង់មកផ្ដល់សក្ខីកម្មនៅទីនេះទេ ហើយឥឡូវសុំដាក់ទណ្ឌកម្មគាត់។ អ៊ីចឹងគួរឲ្យភ្ញាក់ផ្អើលណាស់។ ខ្ញុំគិតថាមិនចាំបាច់ទទួលយកសំណើរបស់សហព្រះរាជអាជ្ញាទេ។ អ៊ីចឹងគ្រាន់តែសូមរំឭកជូនព្រះរាជអាជ្ញាថា សហភាតារបស់ខ្ញុំទាំងអស់នេះបានលើកឡើងហើយអំពីអំណះអំណាងហ្នឹង។

អ៊ីចឹងការសំណើសុំឲ្យពិចារណានៃសេចក្ដីសម្រេចរបស់ចៅក្រម ដែលបានធ្វើហើយមកហ្នឹងសូមបដិសេធចោលតែម្ដងទៅ។

[០៩:៥៤:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោកតំណាងសហព្រះរាជអាជ្ញា!

មានបញ្ហាអីទៀតហើយលោកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន! ខ្ញុំសូមបញ្ជាក់បន្តិចមុននឹងតំណាងសហព្រះរាជអាជ្ញាឡើងធ្វើ

សេចក្ដីឆ្លើយតប។ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនដែលនិយាយដូចអ្វីដែលលោកស្រី អង់តា ហ្គីសសេ បានលើកនោះទេ គឺមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅតែចង់ឲ្យលោក ស សារិន មកធ្វើសក្ខីកម្មដដែល។ ហើយក៏នៅតែចង់ឲ្យមានការរកវិធានការសមស្របណាមួយដើម្បីឲ្យគាត់បាត់ភ័យ បាត់ព្រួយ ហើយអាចឆ្លើយដោយទុកចិត្តថានឹងមានអ្វីកើតឡើងចំពោះខ្លួនគាត់។

[០៩:៥៥:៤៧]

ដូច្នេះអ្វីដែលលោកស្រី អង់តា ហ្គីសសេ ដែលបាននិយាយថាលោក ស សារិន មិនមានបំណងនៅក្នុងការឆ្លើយ មិនមែនជាការសមស្របទេ។ ផ្ទុយទៅវិញ គាត់ចង់ឆ្លើយដើម្បីឲ្យជូនតុលាការ ហើយក៏ចង់រហូតដល់ឆ្លើយឲ្យសាធារណជនទាំងមូលដឹងអំពីចេតនារបស់គាត់ ឲ្យដឹងអំពីអ្វីដែលគាត់អាចឆ្លើយបាននៅក្នុងការចូលរួមនៅក្នុងការផ្ដល់ការពិតផងដែរ។ អ៊ីចឹងសូមបញ្ជាក់ត្រឹមនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមលើកឡើងជាការឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើងនៅពេលកន្លងមកនេះ។

[០៩:៥៦:៣៦]

ជាដំបូង ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ថា យើងមិនមែនជំទាស់ទៅលើបញ្ហាដែលថាលោក ស សារិន គួរចាត់ទុកជាសាក្សីនោះទេ។ គឺថាយើងចាត់ទុកគាត់គឺជាភាគីនៃកិច្ចដំណើរការនីតិវិធីរបស់យើង ហើយមានកាតព្វកិច្ច មានសិទ្ធិរបស់ភាគីនីមួយៗ។ ពាក់ព័ន្ធទៅនឹងសិទ្ធិអំណាចរបស់អង្គជំនុំជម្រះក្នុងការកោះហៅលោក ស សារិន មកផ្ដល់សក្ខីកម្មនោះ យើងជឿជាក់ថាវាច្បាស់លាស់តាមវិធានផ្ទៃក្នុងដែលបានចែង។ ហើយខ្ញុំនឹងមិននិយាយអំពីវិធានផ្ទៃក្នុងដែលយើងបានដាក់នៅក្នុងសំណើរបស់យើងនោះទេ។ ប៉ុន្តែបើសិនជាតាមវិធាន៤១ ដូចដែលសហការីខ្ញុំបានលើករួចទៅហើយគឺថាវិធាន៤១(១) បានបញ្ជាក់ថា ការកោះហៅ គឺជាការបង្គាប់បញ្ជា -- ការកោះហៅ ដីកាកោះ គឺជាការបង្គាប់ដល់បុគ្គលណាម្នាក់ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ហើយដីកានេះអាចអនុវត្តចំពោះដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ វិធាន៤១(៥) គឺបញ្ជាក់ច្បាស់បន្ថែមតទៅទៀតនេះថា ចាប់ពី

ដំណាក់កាលជំនុំជម្រះឡើងទៅ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានកោះហៅតាមរយៈសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:៥៨:០០]

ហើយខ្ញុំសូមជម្រាបថា នេះជាគឺបទដ្ឋាន ជាស្តង់ដារដែលមិនមែនប្រើប្រាស់តែក្នុងបារាំងទេ គឺមាននៅគ្រប់តុលាការទាំងអស់ គឺថាភាគីនៅចំពោះមុខអង្គជំនុំជម្រះអាចនឹងត្រូវបានកោះហៅដោយតុលាការតាមរយៈមេធាវី។ តុលាការមិនចាំបាច់បង្គាប់បញ្ជាទៅអ្នកណានោះទេ គឺអាចបង្គាប់បញ្ជាទៅដល់ភាគី គឺបង្គាប់បញ្ជាទៅដល់មេធាវីដើម្បីឲ្យមេធាវីធ្វើការកោះហៅមកតែម្តង។ វិធាន៥៩(១) និងវិធាន៥៩(៦) ក៏បានលើកឡើងអំពីបញ្ហាទាំងអស់នេះដែរ។

វិធាន៥៩(១)បានចែងថា “សហចៅក្រមស៊ើបអង្កេតមានសិទ្ធិចេញដីកាកោះហៅក៏ដូចជាសម្ភាសដើមបណ្តឹងរដ្ឋប្បវេណី”។ អ្វីដែលជារឿងគួរឲ្យចាប់អារម្មណ៍នៅក្នុងវិធាន៥៩(៦)ទៀតនោះ គឺបានបញ្ជាក់ច្បាស់អំពីលក្ខខណ្ឌមួយចំនួនដែលអាចធ្វើឡើងដោយអ្នកស៊ើបអង្កេតនៃ អ.វ.ត.ក គឺមិនមែនដោយសហចៅក្រមទេ គឺដោយត្រឹមតែអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ហើយក្នុងលក្ខខណ្ឌទាំងអស់នោះគឺមានដូចតទៅនេះ គឺថា “អ្នកស៊ើបអង្កេតអាចសាកសួរដើមបណ្តឹងរដ្ឋប្បវេណី” គឺវិធាន៥៩(៦)(ក) គឺថា “ដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់ការយល់ព្រមរបស់ខ្លួនយ៉ាងច្បាស់ ហើយការយល់ព្រមនេះត្រូវមានចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយ”។

[០៩:៥៩:៣២]

លក្ខខណ្ឌតម្រូវនៃការយល់ព្រមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺអនុវត្តតែនៅក្នុងការសម្ភាសដោយអ្នកស៊ើបអង្កេតនៃ អ.វ.ត.ក ដែលត្រូវបានអនុវត្តតាមដីកាចាត់ឲ្យស៊ើបសួរជំនួសតែប៉ុណ្ណោះ។ ដូច្នេះបញ្ហានេះគឺមិនអនុវត្តចំពោះការសម្ភាសដោយចៅក្រម ឬក៏ដោយមានការព្រមព្រៀងពីដើមបណ្តឹងរដ្ឋប្បវេណីដែលយល់ព្រមមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះទេ។

ហើយខ្ញុំសូមបញ្ចប់វិធានដោយសង្ខេបគឺវិធាន៥៥ មួយទៀត ហើយខ្ញុំគិតថា ប្រហែលជាយើងអាចដោះស្រាយជាមួយវិធាន៣៥ផងដែរ។ វិធាន៣៥ ប្រើប្រាស់ចំពោះគ្រប់បុគ្គលទាំងអស់។ ទាក់ទងទៅនឹងបុគ្គលដែលមិនគោរពទៅតាមការកោះហៅរបស់តុលាការគឺវិធាន៣៥ ផ្តល់នូវការណែនាំទាំងអស់។

ឥឡូវនេះខ្ញុំសូមបន្តពីសិទ្ធិអំណាច ដែលតុលាការមានក្នុងការចេញដីកាដោះហៅភាគីនានាមក

ចំពោះមុខខ្លួន។ ហេតុផលដែលខ្ញុំស្នើសុំអង្គជំនុំជម្រះមិនឲ្យចាត់ទុកថា ស សារិន គឺជាសាក្សីនៅក្នុងដំណាក់កាលនេះ ព្រោះថាអង្គជំនុំជម្រះមានសិទ្ធិអំណាចលើសភាគីនានាចំពោះសាក្សី។ គឺថាអង្គជំនុំជម្រះមានសិទ្ធិអំណាចច្រើនជាង មិនមែនតិចជាងភាគីនោះទេ។ ភាគីគឺជាបុគ្គលដែលស្ម័គ្រចិត្តចូលមកក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះ ហើយភាគីស្នើសុំឲ្យមានការទូទាត់សំណងតាមរយៈអង្គជំនុំជម្រះក្នុងនាមខ្លួន។ ហើយភាគីដែលបានដាក់ ដែលបានសុំចូលនៅក្នុងយុត្តាធិការរបស់តុលាការ គឺភាគីហ្នឹងត្រូវគោរពទៅតាមដីកា ហើយត្រូវមានកាតព្វកិច្ចអនុវត្តទៅតាមដីការបស់អង្គជំនុំជម្រះ។

[១០:០២:១៨]

គ្មានអ្នកណាម្នាក់និយាយថា លោក ស សារិន មានអភ័យឯកសិទ្ធិ ឬក៏មានសិទ្ធិពិសេសណាមួយនោះទេ។ គាត់មិនមែនជាតុលាការ មិនមែនជាចៅក្រម មិនមែនជាច្បាប់ ហើយគាត់មិនអាចនៅពីលើច្បាប់បាននោះទេ។ ដូច្នេះគឺថាលោក ស សារិន មិនអាចសម្រេចចិត្តដោយខ្លួនឯង ថាតើគាត់ត្រូវផ្តល់សក្ខីកម្មឬក៏អត់នោះ។ នេះគឺជាសិទ្ធិរបស់អង្គជំនុំជម្រះមិនមែនសិទ្ធិរបស់លោក ស សារិន ទេ។ ហើយលោក ស សារិន បានស្ម័គ្រចិត្តធ្វើជាភាគីរបស់កិច្ចដំណើរការនីតិវិធីនេះ ដូច្នេះគាត់ត្រូវទទួលគោរពទៅតាមការបង្គាប់របស់តុលាការ។

យើងបានលើកនូវបញ្ហានេះនៅក្នុងសារណារបស់យើងរួចទៅហើយ។ ហើយមេធាវីការពារក្តី ក៏ដូចជាមេធាវីការពារក្តីមិនអាចជំទាស់ទៅលើបញ្ហានេះបានទេ។ ហើយដូចដែលយើងបានបញ្ជាក់នៅក្នុងសារណារបស់យើង គឺយើងបានបញ្ជាក់ច្បាស់តាមវិធាន៣៥(ជ) -- (ច) -- តាមវិធាន៤៥(ជ) គឺបានបញ្ជាក់ច្បាស់។ ហើយហេតុផលដែលយើងមួយទៀតដែលយើងលើកយកវិធាន៣៨ គឺយើងគិតថាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដូចគ្នានឹងសាក្សី។ ប្រសិនបើស្ថានភាពបានកើតឡើងជាក់ស្តែងដែលថាអាចថានៅពេលដែលមានការឆ្លើយដាក់ខ្លួនឯង គឺថាគាត់អាចប្រើប្រាស់ទៅលើស្ថានភាពនេះ ហើយឥឡូវនេះយើងជួបប្រទះនឹងស្ថានភាពនេះ។

[១០:០៣:១៤]

យើងមិនមែនស្នើសុំឲ្យ ស សារិន ផ្តល់សក្ខីកម្មទាក់ទងទៅនឹងសេចក្តីប្រកាសរបស់ នួន ជា និង ខៀវ សំផន ដែលមានលក្ខណៈប៉ះពាល់នោះទេ។ ការពិតទៅសេចក្តីប្រកាសហ្នឹង គឺជាការដាក់បន្ទុកទៅលើជនជាប់ចោទ មិនមែនដាក់បន្ទុកទៅលើលោក ស សារិន នោះទេ។

លោក លោកស្រីចៅក្រម សក្ខីកម្មរបស់ជនរងគ្រោះ គឺជាផ្នែកដ៏សំខាន់នៃកិច្ចដំណើរការនីតិ វិធី

ព្រហ្មទណ្ឌ។ ជនរងគ្រោះភាគច្រើនមិនតម្រូវឲ្យផ្តល់សក្ខីកម្មនោះទេ មិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មនោះទេ ពួកគេស្ម័គ្រចិត្តមកដើម្បីស្វែងរកយុត្តិធម៌។ ទោះបីថាពួកគាត់មានការព្រួយបារម្ភដ៏សមស្របអំពីសុវត្ថិភាពរបស់ខ្លួនក៏ដោយ គឺគាត់អាចស្វែងរកវិធី វិធានការការពារដ៏សមស្រប។

មានសំណុំរឿងព្រហ្មទណ្ឌមួយចំនួនដែលជនរងគ្រោះគាត់មិនចង់ស្ម័គ្រចិត្តមកសហការ។ នៅក្នុងករណីតុលាការជាតិ ឧទាហរណ៍ដូចជាការអំពើហិង្សាក្នុងគ្រួសារ ឬក៏ការបង្កហិង្សានៅក្នុងគ្រួសារ។ ហើយហេតុផលដែល យើងលើកឡើងអំពីសារណាទាំងអស់នេះ ព្រោះថាវាជាបញ្ហាមូលដ្ឋានពាក់ព័ន្ធទៅនឹងសិទ្ធិអំណាច ក៏ដូចជាអំណាចរបស់តុលាការមួយនេះដែរ។

[១០:០៤:៣៨]

ការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញានៅទីនេះ គឺដើម្បីតំណាងឲ្យផលប្រយោជន៍របស់ប្រជាជន របស់សាធារណៈក្នុងការស្វែងរកការផ្តន្ទាទោស។ ហើយយើងធ្វើដូច្នេះ មិនមែនដើម្បីជាប្រយោជន៍របស់ជនរងគ្រោះនោះទេ។ ហេតុដូច្នេះហើយទើបយើងមានមេធាវីពិសេសមួយទៀត ដែលការងាររបស់ពួកគាត់ គឺតំណាងជាពិសេសដល់ផលប្រយោជន៍ដល់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។ ដើម្បីការពារប្រយោជន៍ជាសាធារណជន វាគឺជាមូលដ្ឋានមួយ ដែលថាគ្រប់តុលាការទាំងអស់ត្រូវតែមានសិទ្ធិអំណាចក្នុងការបង្ខំជនរងគ្រោះឲ្យផ្តល់សក្ខីកម្មនៅក្នុងករណីកម្រណាមួយ ក្នុងករណីដែលចាំបាច់ដែលតម្រូវឲ្យធ្វើបែបនេះ។

ដូច្នេះជនរងគ្រោះគាត់មានសិទ្ធិរបស់គាត់ទាក់ទងទៅនឹងការផ្តល់សក្ខីកម្មរបស់ពួកគាត់។ ក៏ដូចជាលទ្ធភាពក្នុងការការពារអត្តសញ្ញាណរបស់ពួកគាត់ ហើយគាត់អាចមានលទ្ធភាពផ្តល់សក្ខីកម្មជាអសាធារណៈ ឬក៏មាននូវការការពារជាបណ្តោះអាសន្នចំពោះពួកគាត់។ ពួកគាត់មានសិទ្ធិក្នុងការរក្សាសិទ្ធិនៅស្ងៀម មិនផ្តល់សក្ខីកម្ម។

[១០:០៥:៥៨]

លោក លោកស្រីចៅក្រម ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីជាង៤០០០នាក់ដែលបានចូលរួមក្នុងសំណុំរឿងនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះសុទ្ធតែជាមនុស្សល្អ ពួកគាត់ជាជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយគាត់បានចំណាយពេលវេលាយ៉ាងច្រើនដើម្បីក្លាយខ្លួនទៅជាផ្នែកនៃដើមបណ្តឹងរដ្ឋប្បវេណី -- ដើម្បីក្លាយទៅជាផ្នែកនៃកិច្ចដំណើរការនីតិវិធីនេះ ហើយនិងចែករំលែកនូវបទពិសោធន៍ដែលពួកគាត់បានទទួលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

លោក ស សារិន មិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណីប្រភេទនេះទេ ហើយគាត់ក៏មិនមែនជាគំរូសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀតនោះដែរ។ គំរូនៃដើមបណ្ដឹងរដ្ឋប្បវេណីដ៏ល្អ គឺជាបុគ្គល ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីដែលមកចូលក្នុងតុលាការ អង្គុយនៅក្នុងតុកន្លែងនេះ ហើយបានរៀបរាប់អំពីអ្វីដែលគាត់បានឆ្លងកាត់ ហើយពេញចិត្តនឹងផ្ដល់សក្ខីកម្មទាក់ទងទៅនឹងអ្វីដែលគាត់បានជួបប្រទះ។ បុគ្គលទាំងអស់នេះ គឺចាត់ទុកជាដើមបណ្ដឹងរដ្ឋប្បវេណីល្អ។

[១០:០៧:១៣]

ហើយបុគ្គលមួយចំនួនទៀតដែលយើងអាចចាត់ទុកថា ជាដើមបណ្ដឹងរដ្ឋប្បវេណីដ៏ល្អ គឺដើមបណ្ដឹងរដ្ឋប្បវេណីដែលចំណាយពេលវេលាមកអង្គុយនៅខាងក្រោយយើងនេះ ហើយស្ដាប់អំពីកិច្ច-ដំណើរការនីតិវិធី អំពីសំណុំរឿង។ លោក ស សារិន មិនមែនជាប្រភេទមនុស្សបែបនោះទេ ព្រោះថាគាត់ជាកម្មាភិបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលទទួលការបណ្ដុះបណ្ដាលនយោបាយពី នួន ជា ហើយនិង ខៀវ សំផន។

ហេតុដូច្នេះហើយ គឺថាគាត់មានព័ត៌មានពិសេសមួយដែលធ្វើឲ្យគាត់ខុសពីដើមបណ្ដឹងរដ្ឋប្ប-វេណីដទៃទៀត។ ហើយបញ្ហាទាំងអស់នេះ គឺបង្ហាញច្បាស់នៅក្នុងការសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមាននៅចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំសូមកត់សម្គាល់ដោយសង្ខេបថា លោក ស សារិន គឺដឹងយ៉ាងច្បាស់នៅពេលដែលគាត់ផ្ដល់ព័ត៌មានលម្អិតទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលថាព័ត៌មានទាំងអស់នេះ នឹងត្រូវផ្ដល់ជូនតុលាការ។

[១០:០៨:១៦]

នៅពេលដែលគាត់ចាប់ផ្ដើមសម្ភាសដំបូង គឺឯកសារ D230/1.1.874c ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ថា ឯកសារសម្ភាសរបស់គាត់អាចបញ្ជូនទៅតុលាការ ហើយលោក ស សារិន បានឆ្លើយតបថា “បាទ គ្មានបញ្ហាទេ ខ្ញុំរីករាយ ហើយខ្ញុំក៏ចង់ផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការយុត្តិធម៌ នៅចំពោះមុខព្រះរាជអាជ្ញា ទាក់ទងទៅនឹងមេដឹកនាំជាន់ខ្ពស់ទាំងនោះ”។ លោក ស សារិន ក៏បានប្រាប់ផងដែរថា “ខ្ញុំយល់ស្របថា ការសម្ភាសរបស់ខ្ញុំអាចប្រើប្រាស់នៅក្នុងទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺទស្សនាវដ្ដីស្វែងរកការពិត”។ ហើយបន្តមកទៀត គាត់ក៏បានផ្ដល់នូវព័ត៌មានលម្អិតបន្ថែមទៀត ទាក់ទងទៅនឹងសុន្ទរកថារបស់ នួន ជា និង ខៀវ សំផន។

ខ្ញុំមិននិយាយលម្អិតទៅលើអ្វី ដែលខ្ញុំបានលើកឡើងរួចហើយនៅក្នុងសារណាររបស់ខ្ញុំនោះទេ

ប៉ុន្តែចំណុចសំខាន់នៃសុន្ទរកថាទាំងនោះ គឺបានផ្តុះបញ្ចាំងអំពីគោលនយោបាយដែលដៅចំពោះអតីតមន្ត្រីរដ្ឋការ និងទាហាន លន់ នល់។ ជាឧទាហរណ៍ គាត់បានរៀបរាប់អំពីសុន្ទរកថារបស់ នួន ជា ដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ពាក់ព័ន្ធទៅនឹង សេ.អ៊ី.អា យើងត្រូវតែកម្ទេចពួក សេ.អ៊ី.អា អាមេរិក វាជាការងាយក្នុងកម្ទេច--

[១០:០៩:៤២]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន លោកតំណាងសហព្រះរាជអាជ្ញា មានការជំទាស់តវ៉ាពីមេធាវីការពារក្តីលោក ខៀវ សំផន។

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមអន្តរាគមន៍។ ខ្ញុំសូមជំទាស់ទៅនឹងសហព្រះរាជអាជ្ញា ខ្ញុំនឹងសួរថាតើត្រូវពិចារណាឡើងវិញ អំពីសំណើរបស់សហព្រះរាជអាជ្ញាយ៉ាងណានោះ ឬក៏ថាអំណះអំណាងរបស់គាត់អម្បាញ់មិញនេះ សួរថាត្រូវបង្ខំគាត់ ឲ្យសាក្សីនេះមកឲ្យផ្តល់សក្ខីកម្មនៅទីនេះ ឬក៏អត់នោះ។ ខ្ញុំគិតថាយើងកំពុងតែប្រាសឃ្លាតចេញពីកម្មវត្ថុនៃសវនាការយើងហើយ។ អ៊ីចឹងគាត់កំពុងតែនិយាយការសន្និ-ដ្ឋានចុងក្រោយ។ អ្វីដែលគាត់រំពឹងរង់ចាំអំពីសក្ខីកម្មរបស់លោក ស សារិន នោះមិនត្រូវនិយាយនៅពេលនេះទេ។

[១០:១០:៤១]

អ៊ីចឹងខ្ញុំគិតថា ភាគីទាំងអម្បាលម៉ានដែលនិយាយអម្បាញ់មិញនេះ លើកអំណះអំណាងនោះថាតើយើងត្រូវបង្ខំគាត់មកទីនេះ ឬក៏អត់ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សី។ ហើយចំណុចនេះសំខាន់ណាស់ ខ្ញុំសូមរំឭកម្តងទៀត គឺថាមានចំណុចមួយដែលសំខាន់មិនទាន់បានលើកឡើងនៅឡើយ។ ក៏ប៉ុន្តែមាននៅក្នុងសេចក្តីសម្រេចរបស់តុលាការហើយ គឺឯកសាររបស់ វី.ស៊ូ គឺឯកសារ E29/460 មានកិច្ចសម្ភាសន៍ ស សារិន ដ៏លម្អិត ហើយមានលក្ខខណ្ឌមួយចំនួនដែលគាត់តម្រូវ ហើយដែលគាត់ថាគាត់មិនអាចមកទីនេះបានទេ។

អ៊ីចឹងសូមឲ្យគិតអំពីចំណុចនេះ ហើយកុំមិនបាច់និយាយវែងឆ្ងាយទៀតទេ។ អ្វីដែលរំពឹងទុករបស់សហព្រះរាជអាជ្ញា ឬក៏ការប្រឹងប្រែងបកស្រាយរបស់សហព្រះរាជអាជ្ញាលើពាក្យសម្តីរបស់

លោក ស សារិន នេះមិនមានតម្លៃអីទេនៅទីនេះ។ អ៊ីចឹងសូមឲ្យតុលាការគិតសំខាន់បំផុតទៅលើអ្វីដែលគាត់បានលើកឡើងជូន វី.ស៊ូ អង្គភាពគាំពារសាក្សីលោកប្រធាន។

[១០:១១:៤៥]

**លោក ឌេល លីសាក់៖**

តាមពិតមេធាវី នួន ជា បានជំទាស់ហើយ យើងនិយាយអំពីការគាំទ្រនៃការកោះសាក្សី។ ទី១ គឺសេចក្ដីសម្រេចគឺថាមានកំហុសឆ្គងអង្គច្បាប់ ហើយទី២ គឺបញ្ហាថាតើអង្គជំនុំជម្រះមានអំណាចនឹងកោះហៅ ឬមិនកោះហៅលោក ស សារិន។ អានេះជាសិទ្ធិត្រូវពិភាក្សា។ មូលហេតុទី២ ដែលត្រូវពិចារណា ថាតើត្រូវបម្រើគោលដៅយុត្តិធម៌ដែរឬទេ? ហើយដូចជាការកត់សម្គាល់ទៅលើភស្តុតាងដែលសាក្សីនេះបានផ្ដល់ ដែល ស សារិន បានផ្ដល់ (សូមអភ័យទោសគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីទេ)។ នេះមិនគាត់មិនមែនជាជនសាមញ្ញ ដែលមកជម្រាបតុលាការអំពីបទពិសោធន៍ក្នុងឋានៈជាគាត់ជនរងគ្រោះទេ។ គាត់ជាបុគ្គល គាត់មានភស្តុតាងដ៏រឹងមាំ ដែលទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍ដោយ នួន ជា និង ខៀវ សំផន។

[១០:១២:៤៧]

នោះជាមូលដ្ឋានដែលយើងលើកឡើងថា នឹងបង្ហាញនូវភាពយុត្តិធម៌ បើសិនជា ស សារិន មកបង្ហាញពីភស្តុតាងបែបនោះ។ ដូច្នេះសូមស្នើ លោក លោកស្រីចៅក្រមដើម្បីបញ្ចប់សេចក្ដីដកស្រង់នេះពីព្រោះថាមានសារៈសំខាន់។ យើងមានមេធាវីការពារក្ដីនៅទីនេះ ដែលគាត់អះអាងបន្តហើយបន្តទៀតថាមិនមានភស្តុតាង មិនមានគោលនយោបាយ។ ប៉ុន្តែយើងមានលោក ស សារិន ដែលឆ្លើយយ៉ាងលម្អិតទៅមជ្ឈមណ្ឌលឯកសារកម្ពុជា និយាយពីសុន្ទរកថារបស់ នួន ជា ដែលនិយាយជាក់លាក់អំពីគោលនយោបាយសំដៅទៅ--

**ប្រធានអង្គជំនុំ៖**

ផ្អាកសិនតំណាងសហព្រះរាជអាជ្ញា!

មានការជំទាស់ពីតំណាងតវ៉ាពីមេធាវីទៀតហើយ សូមអញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំកត់សម្គាល់ឃើញថា នេះជាព័ត៌មាន យើងដឹងទាំងអស់ទាក់ទងទៅនឹងអ្វីដែលសាក្សីនោះ -- ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មហើយ មិនមែនជាដំណឹងទេ។

ប៉ុន្តែយើងដឹងថាតើអ្វីជាការកែប្រែថ្មីទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានធ្វើរួចហើយនោះ? ដើម្បីការសមលើកឡើងវិញអំពីសក្ខីកម្មរបស់គាត់ និយាយដូចម្តេចនោះ អាហ្នឹងវាមិនឆ្លើយតបទេ។ ប៉ុន្តែយើងនឹងពិនិត្យមើលថាតើលទ្ធភាពអំពីការកោះហៅសាក្សីរបស់យើងខ្ញុំ TCW-223 នោះផងដែរ។ ប៉ុន្តែការណាមានការសម្រេចទៅហើយ យើងមិនអាចលើកឡើងវិញទេ។ ដូច្នេះគឺថា យើងមិនអាចអះអាងពីអ្វីដែលជាព័ត៌មានដែលអង្គជំនុំជម្រះបានជ្រាបរួចហើយនោះឡើងវិញនោះទេ។

**លោក ផេល លីសាក់៖**

*(គ្មានការបកប្រែ)*

[១០:១៤:៤១]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាគួរតែសង្ខេបបានហើយ ពីព្រោះគោលបំណងរបស់អង្គជំនុំជម្រះលើបញ្ហានេះ មិនមែនផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាឲ្យលើកសាឡើងវិញនូវសំណើសុំរបស់ខ្លួនទេ។ អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា វិធានផ្ទៃក្នុងហ្នឹងមិនមានការចែងអំពីការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួនទេ។ អង្គជំនុំជម្រះសាលាដំបូងមិនធ្វើការពិចារណាលើសំណើពាក់ព័ន្ធទៅនឹងបញ្ហាដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនោះទេ។ ប៉ុន្តែដោយសារបញ្ហានេះមានការពាក់ព័ន្ធសំណើរបស់លោកហ្នឹង គឺមានការពាក់ព័ន្ធទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹងហើយបានមេធាវីការពារក្តី នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកអំមិញអំពីបញ្ហានេះ ដែលកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅនៅចំពោះមុខអង្គជំនុំជម្រះកន្លងមកនេះ មិនមានការដែលមានការខ្វែងគ្នារវាងតំណាងសហព្រះរាជអាជ្ញា ហើយនិងខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ។ ប៉ុន្តែសំណើសុំរបស់លោកមានការប៉ះពាល់ទៅលើសិទ្ធិ និងផលប្រយោជន៍របស់កូនក្តីរបស់គេ។ អ៊ីចឹងហើយបានគេបានលើកឡើងពាក់ព័ន្ធនឹងបញ្ហាហ្នឹង។

[១០:១៥:៤០]

អង្គជំនុំជម្រះមានគោលបំណងផ្តល់វេទិកា ប្រសិនបើមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហាហ្នឹងទៅឲ្យភាគីនៃមេធាវីការពារក្តី។ អង្គជំនុំជម្រះមិនបានគិត និងលៃពេលវេលាសម្រាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី -- តំណាងសហព្រះរាជអាជ្ញាលើកឡើងសាឡើងវិញនូវសំណើរបស់ខ្លួនឡើយ។ សំណើរបស់ខ្លួនបានសរសេរលាយលក្ខណ៍អក្សរសព្វគ្រប់អស់ហើយ។ ប្រសិនបើលោកអាច

ឆ្លើយតប គឺឆ្លើយតបតែកម្រិតត្រឹមតែការលើកឡើងចុងក្រោយនៃមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគ្រប់គ្រាន់ហើយ។ អង្គជំនុំជម្រះនឹងមានមូលដ្ឋានក្នុងការពិចារណានេះហើយ។ អ៊ីចឹងហើយបានអង្គជំនុំជម្រះបានលើកឡើងបញ្ហានេះមុនពេលផ្ដល់វេទិកាជូនទៅភាគីពិចារណាពិភាក្សាលើបញ្ហាដែលពាក់ព័ន្ធ។

**លោក ផេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្ត។ ខ្ញុំសូមកត់សម្គាល់ថា បញ្ហាមួយចំនួនដែលបានលើកឡើង គឺថាមូលដ្ឋានទី៣ ដែលត្រូវលើកឡើងគឺថាគឺទាក់ទងទៅនឹងខ្លឹមសារនៃសក្ខីកម្មនេះ។ ខ្ញុំមិនបញ្ជាក់ឡើងវិញទេនៅក្នុងសារណាពីដើមរបស់ខ្ញុំ។

[១០:១៦:៥០]

ខ្ញុំសូមសន្និដ្ឋានបញ្ចប់ដោយជម្រាបតុលាការថា ការបដិសេធមិនព្រមឆ្លើយធ្វើសក្ខីកម្មនោះហើយនិងផ្ដល់នូវព័ត៌មានដ៏សំខាន់ដែលគាត់មានទៅតុលាការនោះទេ។ ស សារិន បានអាចនឹងធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតចុះខ្សោយ ហើយធ្វើខូចប្រយោជន៍ភាគីដទៃ ខ្លួនគាត់ដែរ។ គាត់បានបំពានគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិ និងកាតព្វកិច្ចរបស់គាត់ដែលដើមបណ្ដឹងរដ្ឋប្បវេណី៣០០០ជាងទៀត ដែលពួកគាត់បានបំពេញកាតព្វកិច្ចដោយមិនមានការបង្ខំ។ ពួកគាត់មានកាតព្វកិច្ចផ្ដល់ព័ត៌មានដែលពាក់ព័ន្ធ បទពិសោធន៍ដែលគាត់មាន។ បើ ស សារិន ចង់ក្លាយជាភាគីនៃដំណើរការនីតិវិធីនេះគាត់ត្រូវតែមកផ្ដល់សក្ខីកម្ម ហើយខ្ញុំសង្ឃឹមថាគាត់អាចនឹងធ្វើបែបនេះដោយស្ម័គ្រចិត្ត។ បើមិនដូច្នោះទេ អង្គជំនុំជម្រះមានអំណាចក្នុងការបង្គាប់ឲ្យគាត់អញ្ជើញមក ហើយអង្គជំនុំជម្រះគប្បីតែធ្វើបែបនោះ។

[១០:១៨:០២]

យើងខ្ញុំសូមជម្រាបថា ការបង្គាប់ឲ្យគាត់មកធ្វើសក្ខីកម្មមិនបំពានទៅលើសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណីទេ។ មិនមែនជាការប្រឈមទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីទេ។ យើងខ្ញុំជឿជាក់ថា វាអាចនឹងពង្រឹងអំពីតួនាទីដ៏សំខាន់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះក្នុងដំណើរការនីតិវិធី។ សារៈសំខាន់នៃភស្តុតាងដែលគេអាចផ្ដល់នោះ ហើយនិងការទទួលខុសត្រូវជាមូលដ្ឋានរបស់ពួកគេជាភាគីនោះ ក្នុងការផ្ដល់នូវភស្តុតាងដែលពាក់ព័ន្ធ ដែលជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត។ ខ្ញុំសូមបញ្ចប់សេចក្ដីសន្និដ្ឋាន ហើយខ្ញុំសូមអរគុណដែលបានផ្ដល់វេទិកាឲ្យខ្ញុំបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំមានសំណួរមួយចោទសួរទៅមេធាវីរបស់លោក ស សារិន។ កាលពីព្រឹកមិញ យើងបានស្តាប់ឮថា បើតាមគាត់លោក ស សារិន ចង់មកផ្តល់សក្ខីកម្មនៅទីនេះ គាត់បានលើកឡើងជាច្រើនដងមកហើយនៅក្នុងសវនាការនេះផងដែរ។

[១០:១៩:២២]

បើអ៊ីចឹងយើងខ្ញុំចង់ដឹងថាតើមេធាវីរបស់លោក ស សារិន ហ្នឹងបានចង់និយាយថាយ៉ាងម៉េចនៅពេលដែលគាត់និយាយថា ស សារិន ចង់មកផ្តល់សក្ខីកម្ម។ តើមានការពិភាក្សាគ្នារវាងលោកមេធាវីហើយនិងកូនក្តីដែរឬទេ ទាក់ទងទៅនឹងសំណើសុំវិធានការការពារ ទាក់ទងទៅនឹងដែនកំណត់ ហើយនិងការដែលអាចធ្វើទៅបាន នៅទាក់ទងនឹងការវិធានការការពាររបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះយើងនេះ?

ខ្ញុំគិតថា អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ហើយថា អង្គភាពគាំពារជនរងគ្រោះបានទទួលសំណើរបស់លោក ស សារិន មួយចំនួន ហើយសំណើទាំងអស់នេះមិនអាចធ្វើបានទេ មិនអាចឆ្លើយតបបានទេ។ អ្វីដែលលោកមេធាវីបានលើកឡើងកាលពីព្រឹកមិញ គឺថាគាត់ចង់មកផ្តល់សក្ខីកម្មនៅទីនេះ ទោះបីជាគ្មានវិធានការការពារក៏ដោយ ឬក៏យ៉ាងណា?

សូមលោកមេធាវីបញ្ជាក់។ គឺថាគាត់ -- គេបានប្រាប់លោក ស សារិន ហើយថា ដើម្បីជាប្រយោជន៍ដល់តុលាការ គាត់ត្រូវតែឆ្លើយផ្តល់ចម្លើយដែលមានប្រយោជន៍ជូនតុលាការ។

[១០:២០:៥៨]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ឆ្លើយតបទៅនឹងសំណួរដែលសួរដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ខ្ញុំសូមបញ្ជាក់ថា លោក ស សារិន នៅតែមានបំណងចង់មកផ្តល់សក្ខីកម្មនៅក្នុងសវនាការដដែល។ ហើយមិនដូចអ្វីដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាថា គាត់មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីល្អ ហើយមិនសូវចាប់អារម្មណ៍នឹងតុលាការនេះទេ គឺគាត់នៅពេលដែលគាត់ទំនេរពីការងារ គឺគាត់តែងតែឆ្លៀតមកចូលរួមនៅក្នុង

សវនាការនេះជានិច្ច។ អ៊ីចឹងអាចចាត់ទុកថាជាដើមបណ្ដឹងរដ្ឋប្បវេណីមួយដែលយកចិត្តទុកដាក់ខ្លាំងបំផុតចំពោះអ្វីដែលកើតឡើងនៅក្នុងសវនាការយើងនេះ។

ដូច្នេះនេះជាចំណុចទី១ ហើយសូម្បីតែថ្ងៃនេះក៏លោក ស សារិន ឆ្លៀតពេលដែលគាត់មមាញឹកខ្លាំងមែនទែនក៏គាត់មកចូលរួមស្ដាប់នូវអ្វីដែលពាក់ព័ន្ធនឹងបញ្ហាគាត់ដែរ។

[១០:២១:៥៣]

ចំណុចទី២ លោក ស សារិន -- យើងបានពិភាក្សាជាមួយនឹងលោក ស សារិន អំពីវិធានការផ្សេងៗនៅក្នុងការធ្វើយ៉ាងណាកុំឲ្យគាត់មានការភ័យព្រួយ នៅពេលដែលគាត់ផ្ដល់សក្ខីកម្ម ទៅនឹងមានអ្វីកើតឡើងចំពោះខ្លួនគាត់។ ហើយដែលជាមូលហេតុដែលធ្វើឲ្យគាត់មានការស្ទាក់ស្ទើរនៅ ក្នុងការផ្ដល់សក្ខីកម្ម។ ជាពិសេសពាក់ព័ន្ធទៅនឹងចំណុចសំខាន់ៗ ដែលជាសេចក្ដីថ្លែងការណ៍ ឬវាជាការបង្រៀនរបស់ជនជាប់ចោទនៅក្នុងឱកាសដែលគាត់បានរៀននៅក្នុងសម័យខ្មែរក្រហមនោះ។

លោក ស សារិន ទោះជាបានពិនិត្យទៅឃើញថា មានវិធានការដែលមានកម្រិតដែលតុលាការនេះអាចផ្ដល់យ៉ាងណាក៏ដោយ ក៏លោក ស សារិន យល់ឃើញថាពុំទាន់មានអ្វីដែលជាសំណើវិធានការដែលសមស្រប ដែលអាចធ្វើឲ្យគាត់មានការទុកចិត្តនៅឡើយទេ។ ហើយលោក ស សារិន នៅតែរក្សាសំណើរបស់គាត់ដូចបានលើកពីមុនៗជូនអង្គជំនុំជម្រះដដែល។ ហើយដែលយើងខ្ញុំយល់ថា អង្គជំនុំជម្រះគួរតែមានការពិនិត្យមើល រកវិធានការណាដែលអាចសមស្របដើម្បីកុំឲ្យលោក ស សារិន មានការភ័យព្រួយនៅក្នុងការប្រើប្រាសសិទ្ធិរបស់គាត់នៅក្នុងការផ្ដល់សក្ខីកម្ម។ ហើយលោក ស សារិន ក៏បានបញ្ជាក់ទៀតថា គាត់មិនចង់ផ្លាស់ប្ដូរលក្ខន្តិកៈរបស់គាត់ពីដើមបណ្ដឹងរដ្ឋប្បវេណីទៅជាសាក្សីនោះដែរ។

បាទ សូមអរគុណ លោកចៅក្រម ប្រសិនបើមានអ្វីដែលថាមិនច្បាស់លាស់ខ្ញុំនឹងឆ្លើយបញ្ជាក់បន្ថែមទៀត។

[១០:២៤:០១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ការសុំបំភ្លឺលើកទី១ នោះគឺថាតើលោក ស សារិន មានវត្តមាននៅក្នុងសាលសវនាការដែរឬទេថ្ងៃនេះ? ខ្ញុំសូមសួរបញ្ជាក់ចំណុចនេះ។

**លោក ពេជ អង្គ៖**

បាទ គាត់មាន ព្រឹកមិញខ្ញុំជួបគាត់នៅទីនេះ។ ហើយតែគ្រាន់តែថាខ្ញុំមើលមិនឃើញគាត់

ប្រហែលជាមានគ្នាច្រើន។ បាទ គាត់មានវត្តមាននៅទីនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២៥:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសារលោក ស សារិន នៅទីនេះហើយ អ៊ីចឹងសូមអញ្ជើញគាត់ចូលមកក្នុងកន្លែងជំនុំជម្រះយើងនេះ សាលជំនុំជម្រះនេះ។ ហើយគាត់នឹងអាចឆ្លើយតបជូនតុលាការនៅព្រឹកនេះតែម្តង ពន្យល់ជូនតុលាការនៅពេលនេះតែម្តង។

*(សម្រាករយៈពេលខ្លី)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការនាំគាត់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ នៅចំពោះមុខអង្គជំនុំជម្រះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:២៧:១៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នេះជាបញ្ហានីតិវិធី គោលបំណងនៃសវនាការដើម្បីស្នើបន្ថែមដែលថា ចង់សួរគាត់អំពីតើគាត់មានទទួលការគំរាមកំហែម? តើគាត់យល់អំពីវិធានការសុវត្ថិភាព? តើនេះគោលបំណងដែលត្រូវអញ្ជើញគាត់មកឲ្យបំភ្លឺ ប្រសិនជាដូច្នោះ គឺថាអាចនឹង -- បាទ បែបនោះមែន គឺថាអាចនឹងសវនាការជាអសាធារណៈ ដើម្បីឲ្យគាត់អាចនិយាយបានអំពីអ្វីអាចជាគំរាមកំហែមដល់សុវត្ថិភាព ហើយនិងអសន្តិសុខផ្ទាល់ខ្លួនរបស់គាត់។ អ៊ីចឹងខ្ញុំស្នើឲ្យសវនាការជាអសាធារណៈវិញ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគិតថា បើសិននិយាយពីវិធានការការពារ យើងត្រូវតែនិយាយនៅក្នុងសវនាការជាអសាធារណៈវិញ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចនឹងយល់ច្រឡំលោកប្រធាន គឺថាយើងអាចធ្វើរួចហើយ តាមអង្គភាពគាំពារអ្នកជំនាញ និងសាក្សី ហើយនិង -- ហេតុអ្វីបានជាយើងពិនិត្យលើបញ្ហានេះឡើងវិញ ជាពិសេសសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬសហព្រះរាជអាជ្ញានោះ។ ហើយហេតុអ្វីគឺថាយើងអាចនឹងបិទទ្វារនៅពេលនេះ បើសិនជាមិនដូច្នោះទេ គឺអាចនឹងមានសំណើបែបនេះនៅលើកក្រោយទៀត បាទ។

[១០:២៩:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៣:៤២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះជម្រាបជូនភាគីថា អង្គជំនុំជម្រះសម្រេចសាកសួរលើបញ្ហានេះនាពេលនេះ គឺជាសាធារណៈ។ ហើយដោយគាត់មានបង្ហាញវត្តមាននៅទីនេះហើយ ហើយទី២ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធហ្នឹងគឺតាំងសំណួរអ្វីផ្សេងទៀតទេ អង្គជំនុំជម្រះនឹងតាំងសំណួរដោយខ្លួនឯងពាក់ព័ន្ធនឹងបញ្ហានេះ ហើយទំនងជាមិនច្រើនសំណួរទេ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញ ស សារិន ចូលមកកន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងបន្ទប់សវនាការនេះ!

*(លោក ស សារិន ចូលក្នុងបន្ទប់សវនាការ)*

[១០:៣៥:៣៨]

**ប្រធានអង្គជំនុំ៖**

ជម្រាបសួរលោក ស សារិន។ អង្គជំនុំជម្រះបានទទួលនូវរបាយការណ៍មកពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញរួចហើយ ពាក់ព័ន្ធនឹងការដែលលោកមិនព្រមមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដោយមានមូលដ្ឋានដូចកាលពីនៅក្នុងសវនាការលើកមុន។ គឺលោកមានក្ដីព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសាររបស់លោក ហើយលោកទាមទារសុំឲ្យអង្គជំនុំជម្រះហ្នឹងមានវិធានការ។ ហើយវិធានការរបស់លោកហ្នឹង គឺវានៅក្រៅសមត្ថកិច្ចនៃអង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំ

ជម្រះសាលាដំបូងនៃ អ.វ.ត.ក នេះមិនអាចអនុវត្តបានទេ។

អ៊ីចឹងហើយបានជាអង្គជំនុំជម្រះបានសម្រេចរួចហើយថា មិនកោះហៅលោកឲ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាជាថ្មីទេ។ ដោយមូលហេតុអង្គជំនុំជម្រះមិនមានយុត្តាធិការផ្ដល់នូវកិច្ចការពារដូចដែលលោក ដូចលោកបានស្នើសុំ។ ដូចជាការដែលលោកស្នើសុំឲ្យចាត់វិធានការដាក់កងកម្លាំងការពារសុវត្ថិភាពលោករហូតដល់អស់មួយជីវិត ឬក៏សុំការផ្លាស់ទីលំនៅទៅនៅក្រៅប្រទេសដើម្បីរស់នៅក្រៅប្រទេសជាដើមនោះ គឺវាមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះទេ។

[១០:៣៧:២១]

ហើយថ្ងៃនេះ គឺបានស្ដាប់នូវមតិយោបល់របស់ភាគី ជាពិសេសក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានប្រើពាក្យមួយថា លោកនឹងស្ម័គ្រចិត្តក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយថែមទាំងបង្ហាញពីវត្តមានរបស់លោកនៅក្នុងសាលសវនាការសាធារណៈនៅទីនេះទៀតផង។

នេះជាការបញ្ជាក់នូវជំហរនៃការផ្លាស់ប្ដូរឆន្ទៈរបស់លោក ពីការដែលប្រកែក -- ដែលអះអាងថាទាល់តែចាត់វិធានការការពារតាមសំណើសុំរបស់លោក ទើបលោកព្រមមកផ្ដល់សក្ខីកម្ម។ បើៗវិធានការផ្សេងទៀតមិនទទួលទេ។

អង្គជំនុំជម្រះសូមសួរថាតើរហូតដល់ពេលនេះ តើលោកមានការផ្លាស់ប្ដូរនូវឆន្ទៈ ពីប្រកែកមិនមកផ្ដល់សក្ខីកម្មដោយសារទាមទារនូវលក្ខខណ្ឌនៃវិធានការការពារដូចអ្វីដែលលោកស្នើសុំ ឬក៏លោកស្ម័គ្រចិត្តមកផ្ដល់សក្ខីកម្មដោយនៅចំពោះមុខអង្គជំនុំជម្រះដោយគ្មានលក្ខខណ្ឌអ្វីទេ?

[១០:៣៨:៣៤]

**លោក ស សារិនៈ**

សូមគោរពលោកចៅក្រម និល ណុន ជាទីគោរពដ៏ខ្ពង់ខ្ពស់ និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំសូមបញ្ជាក់នូវឆន្ទៈ និងគោលជំហររបស់ខ្ញុំដែលមានបំណងចង់មកធ្វើសក្ខីកម្ម និងធ្វើសក្ខីកម្មកន្លងមក ដែលខ្ញុំមានសំណូមពរ ដូចលោកប្រធានបានលើកឡើងហ្នឹង។ នេះវាជាការពិត ក៏ប៉ុន្តែខ្ញុំនៅតែប្រកាន់គោលជំហរអ៊ីចឹង ព្រោះសក្ខីកម្មរបស់ខ្ញុំដែលខ្ញុំប្រុងលើកឡើងហ្នឹង វាពាក់ព័ន្ធវែងឆ្ងាយណាស់ មិនត្រឹមតែប៉ះពាល់ពាក់ព័ន្ធទៅលើលោកគ្រូ ដូចជាលោកអ៊ំ ខៀវ សំផន បង្រៀនខ្ញុំ, លោកអ៊ំ នួន ជា បង្រៀនខ្ញុំទេ។ តែៗលើកពាក្យសម្ដីគាត់ វាប៉ះពាល់លើប្រទេសជិតខាងជាចម្បង។ សុវត្ថិភាពសន្តិសុខរបស់ខ្ញុំហ្នឹងវាៗប៉ះពាល់ខ្លាំងណាស់។ ខ្ញុំគ្រាន់តែលើកជម្រាបហេតុជាលំៗអ៊ីចឹង។ តាមទ្រឹស្ដីរបស់

គាត់បង្រៀនខ្ញុំ ប៉ុន្តែដល់ខ្ញុំលើកឡើងវាប៉ះ ប៉ះដល់មិត្តវៀតណាម ប៉ះដល់មិត្តចិន។ រួចគេតែព្រួគេនិយាយពីរឿងយើង -- អាក្រក់ពីគេ គេខឹងយើងអ្នកនិយាយ។ ផ្នែកនយោបាយគឺវាអ៊ីចឹង។

[១០:៤០:២៨]

អ៊ីចឹងវាប៉ះពាល់លើសុវត្ថិភាពសន្តិសុខខ្លាំងណាស់។ ខ្ញុំនៅតែមានសំណូមពរអ៊ីចឹងដដែលហ្នឹង។ បើមិនការពារខ្ញុំអស់មួយជីវិត ឬក៏ធ្វើឲ្យខ្ញុំនិរទេសខ្លួនទៅនៅទីមានសុវត្ថិភាពនៅបរទេស ប្រទេសដែលខ្ញុំពេញចិត្តនោះទេ ខ្ញុំក៏មិនបញ្ចេញនូវសក្ខីកម្មរបស់ខ្ញុំជូនអង្គសវនាការដែរ។ ដូចខ្ញុំលើកឡើងអ៊ីចឹង ព្រោះមិនមែនត្រឹមតែប៉ះពាល់ដល់មិត្តខ្មែរក្រហមមួយមុខហ្នឹងទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ស សារិន។ លោក លោកស្រីចៅក្រមមានសំណួរអីចង់សួរគាត់ទៀតទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:៤១:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោក ស សារិន ដើម្បីឲ្យច្បាស់ទាំងអស់គ្នា យើងបានស្តាប់សំណើសុំវិធានការការពារ ហើយយើងក៏បានស្តាប់ ហើយនិងបានដឹងអំពីរបាយការណ៍របស់អង្គភាពគាំពារជនរងគ្រោះនិងសាក្សី។ សំណើសុំវិធានការការពាររបស់លោកនោះ យើងមិនអាចឆ្លើយតបបានទេ មិនអាចអនុវត្តបានទេ។ អ៊ីចឹងថ្ងៃនេះ មានសំណួរតែមួយទេដែលចោទឡើង។ តើនៅក្នុងលក្ខខណ្ឌនេះលោកអាចមកផ្តល់សក្ខីកម្មដែរឬទេក្នុងករណីដែលថាមិនមានការឆ្លើយតបទៅនឹងសំណើរបស់លោកនេះ? តើលោកច្បាស់នៅក្នុងសំណួរនេះទេ?

**លោក ស សារិន៖**

បាទ មិនមានទេ។ បើមិនមានវិធានការធ្វើដូចសំណូមពររបស់ខ្ញុំលើកឡើងហ្នឹង គឺខ្ញុំមិនអាចឡើងមកធ្វើសក្ខីកម្មបាទទេ។

[១០:៤២:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ស សារិន។ ឥឡូវនេះលោកអាចចាកចេញត្រឡប់ទៅវិញបានហើយ។

បាទ ចំពោះបញ្ហានេះអង្គជំនុំជម្រះនឹងបញ្ជាក់អំពីសេចក្តីសម្រេចរបស់ខ្លួននៅពេលឆាប់ៗខាងមុខនេះ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៣ នាទី ដល់ម៉ោង ១១:១១ នាទី)*

[១១:១១:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងឆ្លងចូលទៅប្រធានបទមួយទៀត អង្គជំនុំជម្រះសូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសួរបញ្ជាក់ទៅខាងតំណាងសហព្រះរាជអាជ្ញា។ បាទ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ តាមពិតទៅ អង្គជំនុំជម្រះមានសំណួរមួយដើម្បីចោទសួរទៅកាន់សហព្រះរាជអាជ្ញា។ យោងតាមការបង្ហាញខ្លួនរបស់លោក ស សារិន កាលពីព្រឹកមិញនេះ ហើយនិងការបង្ហាញជំហររបស់គាត់ដដែលនោះ តើសហព្រះរាជអាជ្ញានៅតែរក្សាសំណើរបស់ខ្លួនពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ស សារិន នេះដដែល ឬក៏សហព្រះរាជអាជ្ញាដកចេញវិញនូវសំណើរបស់ខ្លួននោះ?

[១១:១២:៤៣]

**លោក ឌេល លីសាក់៖**

សូមអរគុណចៅក្រម ឡាវែន៍។ ខ្ញុំ-- យើងខ្ញុំសូមឆ្លើយថា យើងរក្សាយើងរក្សាសំណើរបស់យើងនៅដដែល ហើយយើងខ្ញុំយល់ថាមិនមែនជាសេចក្តីសម្រេចស្ថិតនៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ថាត្រូវធ្វើដូចម្ដេចទេ គឺជាសិទ្ធិអំណាចរបស់តុលាការក្នុងការសម្រេច ថាតើតុលាការត្រូវតែមានអំណាចបង្ខំដើម្បីពង្រឹងរដ្ឋប្បវេណីឲ្យផ្ដល់នូវព័ត៌មានដែលយើងត្រូវការ។ ដូច្នេះ ចម្លើយរបស់ខ្ញុំទៅនឹងលោកចៅក្រមថាយើងខ្ញុំនៅរក្សាសំណើរបស់យើងខ្ញុំដដែល។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសលើកឡើងនូវបញ្ហាចំនួនពីរ។ ទី១ គឺពាក់ព័ន្ធទៅនឹងសំណើសុំឲ្យធ្វើសេចក្ដីសន្និដ្ឋានផ្ទុយប្រឆាំងទៅនឹងជនជាប់ចោទ ខៀវ សំផន និង នួន ជា និងទី២ ពាក់ព័ន្ធទៅនឹងសំណើសុំទទួលយកឯកសារភស្តុតាង និងការដាក់ចំណាត់ថ្នាក់ឯកសារលេខ E3។ ហើយភាគីដទៃទៀតក៏នឹងត្រូវបានអនុញ្ញាតផ្ដល់នូវមតិយោបល់ ឬក៏ធ្វើការឆ្លើយតបចំពោះសំណើនេះដែរ។

សូមអញ្ជើញ!

[១១:១៤:០៧]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយសង្ខេបទៅលើបញ្ហាទាំងពីរនេះ។ បញ្ហាទី១គឺសំណើសុំដែលយើងបានធ្វើជាលាយលក្ខណ៍អក្សរ ទាក់ទងទៅនឹងបញ្ហានិយាយអំពីស្នើឲ្យការប្រើនូវសេចក្ដីសន្និដ្ឋានផ្ទុយ នៅក្នុងករណីដែលជនជាប់ចោទមិនឆ្លើយតបទៅនឹងសំណួរ។ ខ្ញុំមិនលើកឡើងអំពីដែលយើងលើកឡើងពីមុនទេ។ ហើយយើងខ្ញុំចង់ជម្រាបតុលាការ ហើយខ្ញុំស្នើថាដូចដែលយើងបានជិតទៅដល់ការបញ្ចប់នូវការដេញដោលនោះហើយ។ អ្វីដែលយើងត្រូវចង់ធ្វើនោះ គឺយើងត្រូវកំណត់កាលវិភាគមួយ -- ពេលមួយ ដើម្បីឲ្យសហព្រះរាជអាជ្ញាដើម្បីដាក់ -- ឲ្យសហព្រះរាជអាជ្ញាបញ្ជូនទៅជនជាប់ចោទនូវប្រធានបទមួយចំនួនដើម្បីបង្កើតកំណត់ត្រាតុលាការ ថាបញ្ហាទាំងអម្បាលម៉ាននេះ គឺជនជាប់ចោទបដិសេធមិនព្រមឆ្លើយ។ នេះជាកត្តាសំខាន់ដូចដែលយើងខ្ញុំបញ្ជាក់ក្នុងសំណើ។ ដើម្បីឲ្យមានមូលដ្ឋាន ហើយនិងកំណត់ត្រាតុលាការ ដើម្បីអាចនឹងតុលាការប្រើសេចក្ដីសន្និដ្ឋានផ្ទុយបាន។ ហើយយើងខ្ញុំបានបញ្ជាក់នៅក្នុងចុងបញ្ចប់នៃសំណើនៅថ្ងៃទី១៦ កក្កដា គឺឯកសារ E288/4/1 បាទ។

[១១:១៥:៤២]

យើងខ្ញុំស្នើសុំឲ្យមានឱកាសនៅក្នុងតុលាការ ក្នុងសវនាការក្នុងវត្តមានរបស់ជនជាប់ចោទ ដើម្បីដាក់ជូនជនជាប់ចោទនូវបញ្ជីប្រធានបទ ហើយនិងសូមឲ្យពួកគាត់បញ្ជាក់អំពីការបដិសេធក្នុងការឆ្លើយ

ទៅនឹងប្រធានបទនោះ។ និយាយអំពីពេលវេលាវិញ តាមការប៉ាន់ប្រមាណរបស់ខ្ញុំ គឺថាពិបាកនឹងគ្រោងទុក ដែលថាតើត្រូវធ្វើដូចម្ដេច? ប៉ុន្ដែយើងមិនត្រូវការលើសពី១ម៉ោងទេ ដើម្បីនឹងធ្វើការងារនោះបាទ។ នេះជាបញ្ហាអំពីទាក់ទងទៅនឹងសេចក្ដីសន្និដ្ឋានផ្ទុយប្រឆាំងនឹងជនជាប់ចោទនោះ។

ចំណុចទី២ គឺនិយាយពីការរៀបចំខាងកិច្ចការរដ្ឋបាលរបស់តុលាការទេ អំពីការទទួលយកនូវឯកសារជាភស្ដុតាង។ មុនពេលសវនាការស្ដាប់ភស្ដុតាងនឹងបញ្ចប់ ហើយនិងមានសេចក្ដីសម្រេចទៅលើការទទួលយកនូវឯកសារដែលបានបង្ហាញជូននោះ ជាក់ស្ដែងដើម្បីឲ្យយើងខ្ញុំអាចនឹងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់បាន ដែលយើងកំពុងតែរៀបចំនោះ គឺថាដើម្បីឲ្យយើងខ្ញុំថាតើភស្ដុតាងអ្វីខ្លះដែលត្រូវបានទទួលយក ហើយភស្ដុតាងណាខ្លះដែលត្រូវបានបដិសេធនោះ។

[១១:១៧:០៨]

ហើយមានបញ្ហាមួយចំនួន ប្រភេទឯកសារទូទៅមួយចំនួន ដែលយើងខ្ញុំរង់ចាំការសម្រេចដែលទាក់ទងទៅនឹងចម្លើយរបស់សាក្សី ថាតើចំនួនច្រើន មួយចំនួនដែលយើងដាក់នៅក្នុងសំណើ នៅក្នុងទទ្បីករណ៍ ហើយនិងប្រភេទមួយចំនួនទាក់ទងទៅនឹងឧបសម្ព័ន្ធ និងឯកសារថ្មីៗជាដើម។ ហើយយើងក៏បានកត់សម្គាល់ផងដែរ គឺចង់ជម្រាបជូនតុលាការជ្រាប គឺថាម្ដងម្កាលយើងបានរកឃើញឯកសារដែលយើងយល់ឃើញថា អាចនឹងទាងក់ទងទៅនឹងមិនទាន់បានទទួលឯកសារ E3 ឋានៈជាឯកសារ E3 ទេ ដូចជាឯកសារទង់បដិវត្ត នៅក្នុងពេលដែលយើងដាក់បង្ហាញជូនអង្គជំនុំជម្រះ ក៏នៅតែជាឯកសារ D នៅឡើយ។

ដូច្នេះ តាមចំពោះយើងខ្ញុំ ខ្ញុំយល់ថាជាបញ្ហាត្រូវចោទនិងត្រូវដោះស្រាយ។ ឯកសារមួយចំនួនដែលមានទម្រង់ជាអ៊ីម៉ែលនោះផងដែរ។ ប៉ុន្ដែនេះជាចំណុចរបស់យើង ដើម្បីឲ្យភាគីអាចនឹងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់បាន យើងខ្ញុំត្រូវតែដឹងអំពីថាឯកសារណាដែលត្រូវបានទទួលយក ហើយថាតើតុលាការនឹងសម្រេចឲ្យចំណាត់ថ្នាក់ឯកសារជា E3 នៅពេលណាបានឲ្យបានឆាប់ ឲ្យបានទាន់ពេល។

ដូច្នេះនេះជាបញ្ហាដែលខ្ញុំចង់លើកឡើងទាំងពីរចំណុច ឆ្លើយបន្ថែមជូនអង្គជំនុំជម្រះប៉ុណ្ណេះ។ សូមអរគុណ។

[១១:១៨:៤៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញស្រីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមលើកឡើងដោយសង្ខេបលោកប្រធាន។ យើងខ្ញុំគាំទ្រទៅនឹងសំណើទាំងពីររបស់សហព្រះរាជអាជ្ញា។ សំណើទី១ ពាក់ព័ន្ធទៅនឹងការនៅស្ងៀមស្ងាត់ដោយអន្លើរបស់លោក ខៀវ សំផន។ យើងគាំទ្រទៅលើសារណាដែលដាក់សហព្រះរាជអាជ្ញាគឺ E288/4/1 ហើយយើងក៏គាំទ្រទៅលើការសំណើសុំបង្ហាញប្រធានបទនៃការសួរសំណួរនៅក្នុងសវនាការផងដែរ។

ពាក់ព័ន្ធទៅនឹងសំណើទី២ ស្តីអំពីឯកសារនោះ យើងខ្ញុំក៏ចង់បានការសម្រេចរបស់អង្គជំនុំជម្រះឲ្យបានលឿន ដើម្បីដែលបញ្ជាក់ឯកសារណាទទួលបានលេខ E3 ហើយឯកសារណាខ្លះដែលទទួលយកដើម្បីឲ្យយើងធ្វើការពាក់ព័ន្ធទៅនឹងសារណាចុងក្រោយ។ គឺជាពិសេសពាក់ព័ន្ធទៅនឹងឯកសារ៥២០ ដែលយើងបានដាក់កាលពីខែមីនា។ ដូច្នេះយើងខ្ញុំគាំទ្រទៅលើសំណើទាំងពីររបស់សហព្រះរាជអាជ្ញា។

[១១:១៩:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះខាងក្រុមមេធាវីការពារក្តី តើមានមតិយោបល់ ឬក៏មានសេចក្តីតបអ្វីទេចំពោះសំណើសុំទាំងពីររបស់សហព្រះរាជអាជ្ញានេះ?

ជូនក្រុមមេធាវីការពារក្តីលោក នួន ជា មុនបាទ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំនឹងជម្រាបជូនដោយសង្ខេប យើងគាំទ្រសំណើទី២ ដោយសហព្រះរាជអាជ្ញា ហើយមេធាវីការពារក្តីក៏ត្រូវការសេចក្តីសម្រេចឲ្យបានឆាប់ ថាតើឯកសារណាដែលនឹងទទួលបានចំណាត់ថ្នាក់ E លេខ E។

[១១:២០:៤០]

ហើយខ្ញុំសូមជម្រាបអង្គជំនុំជម្រះអំពីសំណើដែលយើងបានដាក់ជូន ដែលយើងខ្ញុំបានបញ្ជូនជាឯកសារចម្លងដែរនោះ គឺថាយើងខ្ញុំបានស្នើ។ យើងឃើញថា អង្គជំនុំជម្រះទំនងជាជិតដល់ចេញសេចក្តីសម្រេចក្នុងការទទួលយកឯកសារ១.៥០០ ដែលថានៅក្នុងឯកសារនេះ គឺថាទាក់ទងនឹងបញ្ហានេះ យើងបានដាក់ស្នើមួយចំនួនទាក់ទងទៅនឹងគោលនយោបាយដែលគេអះអាងថា បានសំដៅទៅរកអតីតមន្ត្រីសាធារណរដ្ឋហ្នឹង គឺថាការបកប្រែហ្នឹងអាចបញ្ចប់នៅថ្ងៃព្រហស្បតិ៍ ហើយខ្ញុំ -- យើងនឹងអាចជូននៅពេលនោះ។ អ៊ីចឹងជូនជាឯកសារជ្រាបជាមុន ហើយយើងភ្ជាប់ជាឯកសារ *ហ្វីប៊ីស* គឺថាអាចបញ្ជាក់

ជាឯកសារវត្ថុតាង គឺថាអាចបញ្ជើឯកសារ១១០ ដែលថាសាក្សីដែលបានឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១១:២១:៤៩]

ហើយខ្ញុំសូមជម្រាបឲ្យអង្គជំនុំជម្រះពិចារណា ពិនិត្យឯកសារទាំងអស់នេះ ដើម្បីឲ្យអង្គជំនុំជម្រះផ្ដល់អាទិភាព ដើម្បីផ្ដល់ជាចំណាត់ថ្នាក់ជាឯកសារ E ដើម្បីពិចារណា។ ហើយសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ដើម្បីសម្រេចឋានៈឯកសារជាចំណាត់ថ្នាក់ E នោះ គឺ -- ហើយយើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាសម្រេចលើឯកសារយើងខ្ញុំស្នើជាអាទិភាព ប៉ុន្តែយើងគាំទ្រជំហររបស់សហព្រះរាជអាជ្ញា យើងចង់ឲ្យមានសេចក្ដីសម្រេចហ្នឹងឲ្យបានឆាប់ ដើម្បីឲ្យយើងច្បាស់ថា តើឯកសារណាដែលតាមពិតទទួលបានចំណាត់ថ្នាក់ E ហ្នឹង។

ទាក់ទងទៅនឹងការសេចក្ដីសន្និដ្ឋានផ្ទុយវិញ យើងខ្ញុំពិតជាយល់ឃើញថា បញ្ហាហ្នឹងគឺវាចោទត្រង់ថា នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលនេះឯង។ ប៉ុន្តែឥឡូវនេះ គឺថាយើងយល់ឃើញថាការបញ្ជូនបញ្ជើសំណួរទៅកូនក្ដីរបស់ខ្ញុំថា តើសំណួរណាត្រូវសួរមិនសួរនោះ យើងអាចនឹងប្រមើលថាប្រធានបទទាំងអស់នោះ ដែលសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខហ្នឹង នឹងមានអ្វីខ្លះ គឺថាតើវាមានភាពពាក់ព័ន្ធដូចម្ដេច។ ប៉ុន្តែនៅទីបំផុត គឺថាអាចនឹងមានសេចក្ដីសម្រេចដែលអង្គជំនុំជម្រះសាលាដំបូងអាចនឹងៗសម្រេចទៅលើបញ្ហានេះ។ ប៉ុន្តែដំណាក់កាលនេះ មិនមានអ្វីដែលថាអង្គជំនុំជម្រះអាចនឹងឆ្លើយតបទៅនឹងប្រធានបទនេះបាននោះទេ។

[១១:២៣:៣២]

និយាយអំពីការប្រើសេចក្ដីសន្និដ្ឋានផ្ទុយនេះ យើងមិនដឹងថា គោលបំណងដើម្បីចង់បានអ្វីទេនៅនេះ ដែលចង់ដាក់ប្រធានបទពាក់ព័ន្ធទាក់ទងទៅនឹងសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោល ប៉ុន្តែយើងខ្ញុំសូមជំទាស់អំពីអ្វីដែលភាគីបានលើកឡើង គឺថាមេធាវី នួន ជា បានដឹងអំពីច្បាប់ករណី ហើយនិងច្បាប់ថាតើអ្វីជាសេចក្ដីសន្និដ្ឋានផ្ទុយនោះ គឺថាយើងៗនឹងលើកឡើងពីបញ្ហានេះដែលត្រូវជម្រាបជូនតុលាការនៅក្នុងពេលដែលយើងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោល។ នៅពេលនេះ គឺយើងមិនឃើញមានភាពបន្ទាន់ ភាពចាំបាច់ដើម្បីលើកឡើងអំពីបញ្ហានេះទេ។ យើងទទួលបាន -- យើងបានទទួលការណែនាំពីកូនក្ដី ហើយយើងបានជម្រាបកូនក្ដីរបស់យើងហើយថា បើសិនជាធ្វើបែប -- គាត់នៅរក្សាការស្ងប់ស្ងៀមមិនឆ្លើយតបនុ៎ង តើនឹងមានផលប៉ះពាល់ដូចម្ដេច?

[១១:២៤:៤៧]

ដូច្នេះយើងនឹងជូនដំណឹងមកអង្គជំនុំជម្រះវិញ បាទ គឺថាអាចនឹងក្នុងករណីដែលមានការប្រែប្រួលយើងនឹងជូនដំណឹងថា តើគាត់ដកសេចក្តីសម្រេចរបស់គាត់មកវិញ ឬដូចម្តេច? ដូច្នេះ យើងនៅច្បាស់ហើយ គាត់បានដកនូវសេចក្តីសម្រេចរបស់គាត់ថា គាត់ឈប់និយាយ គាត់ត្រូវរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ ហើយគាត់នឹងព្យាយាមធ្វើបែបនោះនៅឡើយទេ។ ទាំងអស់នេះគឺថានៅទីបញ្ចប់គឺអង្គជំនុំជម្រះត្រូវពិចារណានៅពេលដែលត្រូវសេចក្តីសម្រេច។ ដូច្នេះនៅពេលនេះ គឺយើងមិនបញ្ជាក់ពីបញ្ហានេះឡើងវិញទេ ដើម្បីឲ្យតុលាការសម្រេចនៅពេលនេះនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេប ពីព្រោះថាយើងខ្ញុំចង់ឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណាលេខ E288/4/1 របស់សហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែខ្ញុំចង់លើកឡើងជាផ្លូវការនូវអ្វីដែលយើងបានលើកឡើងមកហើយកាលពីសវនាការលើកមុននៅចំពោះមុខអង្គជំនុំជម្រះនេះ គឺយើងគិតថាការបង្ហាញអំពីប្រធានបទដែលសហព្រះរាជអាជ្ញាយល់ឃើញថាឲ្យមានការសន្និដ្ឋានផ្ទុយនោះ យើងចង់បង្ហាញនៅពេលនេះ វាជាផ្នែកមួយនៃៗការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលចុងក្រោយ។

[១១:២៦:៣៣]

ក៏ប៉ុន្តែមេធាវីការពារក្តី ខៀវ សំផន បានទទួលការបកប្រែសំណើរបស់សហព្រះរាជអាជ្ញាជាភាសាបារាំងមាន១៤ទំព័រ យើងគិតថាវាជាបញ្ហាសំខាន់ ពីព្រោះថាយើងមិនយល់ យើងមិនបកស្រាយទៅលើអត្ថបទដូចគ្នាដែលលើកឡើងបានដោយសហព្រះរាជអាជ្ញា។ ដូច្នេះយើងគិតថា យើងត្រូវតែធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរដោយយោងទៅលើយុត្តិសាស្ត្រដែលបានលើកឡើង។

ជាគោលការណ៍ គឺថាយើងជំទាស់ទៅនឹងសំណើរបស់ព្រះរាជអាជ្ញា ក៏ប៉ុន្តែចម្លើយជាលាយ-លក្ខណ៍អក្សរនោះនឹងដាក់ជូនអង្គជំនុំជម្រះនៅពេលក្រោយ។

ចំណុចទី២ ពាក់ព័ន្ធទៅនឹងការផ្តល់លេខកូដ E3 ហើយនិងការមានបញ្ជីឯកសារ E3 ច្បាស់លាស់ដល់អង្គជំនុំជម្រះនោះ យើងបានលើកឡើងហើយកាលពីសវនាការមុនៗ ជាពិសេសសវនាការ

កិច្ចប្រជុំរៀបចំសវនាការរៀបចុងក្រោយនោះ យើងខ្ញុំយល់ថាយើងទាំងអស់គ្នាគឺឯកភាពហើយនៅក្នុងសវនាការនេះថា ចំណុចនេះជាចំណុចសំខាន់ដែលយើងចង់ដឹងថាតើឯកសារណាខ្លះដែលត្រូវបានអង្គជំនុំជម្រះទទួលយក ហើយឯកសារណាខ្លះដែលអង្គជំនុំជម្រះនឹងយកធ្វើមកធ្វើជាមូលដ្ឋាននៅក្នុងក្របខ័ណ្ឌនៃការពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះ។

[១១:២៧:៥៩]

ខ្ញុំចូលដល់ចំណុចទី៣ ដែលលើកឡើងនៅក្នុងសវនាការមុនៗហើយៗក៏ប៉ុន្តែវាមានទំនាក់ទំនងទៅនឹងឯកសារ E3 ពីព្រោះវាជាបញ្ហាបកប្រែដែលយើងបានលើកឡើងរួចមកហើយ ហើយនិងការស្នើសុំពេលវេលាបន្ថែមដើម្បីអាចពិនិត្យមើលឡើងវិញនូវប្រតិចារឹកសវនាការ។ យើងខ្ញុំបានលើកឡើងអំពីបញ្ហានេះមកហើយ នៅពេលដែលយើងលើកអំពីបញ្ហាបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារដែលនាំឲ្យមានការបកប្រែផ្ទុយអត្ថន័យ ជាពិសេសនៅពេលដែលសាក្សីមកផ្ដល់សក្ខីកម្មនោះ។

ដូច្នេះមេធាវីការពារក្ដី ខៀវ សំផន ប្រហែលជាយើងមិនមែនតែភាគីតែមួយទេ ខាងដើមបណ្ដឹងរដ្ឋប្បវេណីក៏អ៊ីចឹងដែរ យើងធ្វើការពាក់ព័ន្ធទៅនឹងកំណត់ប្រតិចារឹកជាភាសាខ្មែរ -- ជាភាសាបារាំង (សូមទោស)។ ដូច្នេះហើយយើងចង់ឲ្យមានការពិភាក្សាគ្នាឲ្យបានច្បាស់អំពីឯកសារទាំងអស់នោះ ហើយយើងស្នើសុំពេលវេលាបន្ថែមដើម្បីពិនិត្យមើលប្រតិចារឹកសវនាការទាំងអស់។ នេះជាចំណុចសំខាន់។

គឺថាយើងខ្ញុំកំពុងតែធ្វើអំពីបញ្ហាហ្នឹងហើយ ហើយនៅក្នុងក្រុមយើងនេះគឺថាយើងកំពុងតែពិនិត្យមើលប្រៀបធៀបទៅលើការបកប្រែទាំងអស់ហ្នឹង ហើយនិងមានសារណាដែលនឹងដាក់ពាក់ព័ន្ធទៅនឹងបញ្ហាបកប្រែនេះ។

[១១:២៨:១៥]

អ៊ីចឹងខ្ញុំជម្រាបជូនអង្គជំនុំជម្រះជាមុនឲ្យហើយនៅពេលនេះ។ ពីព្រោះថាវាអាចមានការពិភាក្សាគ្នាចុងក្រោយដែលអាចជាបញ្ហាដូចគ្នាចំពោះភាគីទាំងអស់សម្រាប់ចៅក្រមដែលជាចៅក្រមខ្មែរ ចៅក្រមបារាំង ចៅក្រមអង់គ្លេស ហើយនិងភាគីទាំងអស់។ នេះជាចំណុចសំខាន់ណាស់។

ចំណុចនេះយើងភ្ជាប់ទៅនឹងបញ្ហាឯកសារ E3 ពីព្រោះយើងត្រូវតែដឹងថាតើយើងត្រូវផ្ដោតទៅលើឯកសារណាខ្លះដើម្បីសរសេរសារណាបញ្ចប់ការពិភាក្សាដេញដោលនោះ។ នេះជាអ្វីដែលខ្ញុំចង់លើកឡើងនូវដំណាក់កាលនេះ ហើយសូមអរគុណដែលអង្គជំនុំជម្រះបានផ្ដល់វេទិកានេះជូនខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អង្គជំនុំជម្រះសូមជម្រាបភាគីថា អង្គជំនុំជម្រះនឹងលើកយកបញ្ហានេះទៅពិភាក្សាសម្រេច ហើយនៅចុងក្រោយនៃសវនាការថ្ងៃនេះ។ បាទ ជាបន្តទៅនេះពាក់ព័ន្ធទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដែលបានស្នើសុំឲ្យកោះហៅសាក្សីដែលពាក់ព័ន្ធនឹងគោលនយោ-បាយដែលត្រូវចោទប្រកាន់ក្នុងការវាយប្រហារមន្ត្រីសាធារណៈខ្មែរនោះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើដែលបានផ្ញើមកក្រៅផ្លូវការជាបឋមនោះមានតែភាសាអង់គ្លេស ហេតុនេះអង្គជំនុំជម្រះសុំអញ្ជើញលោកមេធាវីបង្ហាញដោយសង្ខេបនូវទឡ្ហីករណ៍នេះជូនដល់អង្គជំនុំជម្រះ។ ហើយភាគីដទៃទៀតក៏នឹងត្រូវអនុញ្ញាតឲ្យឆ្លើយតបដែរ។

សូមអញ្ជើញលោកក្រុមមេធាវីការពារលោក នួន ជា!

[១១:៣១:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេបអំពីបញ្ហានេះ។ ទាក់ទងទៅនឹងទឡ្ហីករណ៍ដែលមានចែងនៅក្នុងសំណើជាលាយលក្ខណ៍អក្សររបស់យើង ដែលខ្ញុំបានបញ្ជាក់ថា ប្រហែលជានឹងបកប្រែរួចរាល់នៅថ្ងៃព្រហស្បតិ៍។ យើងក៏សូមនិយាយយោងផងដែរទៅលើកំណត់ត្រា ប្រហែលជា៥០.០០០ ដែលត្រូវទទួលនូវការចាត់ចំណាត់ថ្នាក់ជាឯកសារ E3 នោះជាង៥០.០០០ ឯកសារជាង១.៥០០ ឯកសារដែលត្រូវទទួលការចំណាត់ថ្នាក់ជាឯកសារ E3។ ទឡ្ហីករណ៍សំខាន់ដែលយើងចង់លើកឡើងនៅក្នុងសំណើនេះគឺថា គឺជាភស្តុតាងដែលផ្ទាល់ទាក់ទងនឹងគោលនយោបាយក្នុងការសម្លាប់មន្ត្រីនិងទាហានរបបខ្មែរសាធារណរដ្ឋ។ យើងបានលើកឡើងនូវចំណុចដូចគ្នានេះផងដែរ នៅក្នុងចម្លើយតបរបស់យើងទៅនឹងការធ្វើបទបង្ហាញរបស់ព្រះរាជអាជ្ញា ចំពោះឯកសារជាគន្លឹះកាលពីប៉ុន្មានសប្ដាហ៍កន្លងមក។

[១១:៣២:៣៦]

យើងក៏សង្កេតឃើញផងដែរ ពេលលទ្ធភាពនៃការលើកទឡ្ហីករណ៍ដែលបង្ហាញដោយសហព្រះរាជអាជ្ញាដែលថាអាចមានលទ្ធភាពនៃការបង្កើតគោលនយោបាយនេះ ហើយលទ្ធភាពហ្នឹងគឺថាមួយផ្នែកគេធ្វើឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ ៧៥ ដល់ ៧៩។ ហើយក្នុងនោះវាមានឯកសារប្រហែលជា១១០ ឯកសារដែលនិយាយអំពីការផ្ដោតគោលដៅទៅលើមន្ត្រី និងទាហានរបបខ្មែរ

សាធារណរដ្ឋ។ ហើយយើងបានបញ្ជាក់នៅក្នុងសំណើនោះផងដែរថារហូតមកដល់ពេលនេះ នៅពេលដែលយើងធ្វើការដេញដោលទៅលើសាក្សីទាំងអស់នេះ គឺសាក្សីទាំងអស់នេះហាក់ដូចជាមិនអាចទុកចិត្តបាននៅគ្រប់ចំណុចទាំងអស់នៃសក្ខីកម្មរបស់ពួកគាត់។ ហើយក៏ដូចជាចម្លើយជាច្រើនដែលភាគច្រើនពាក់ព័ន្ធទៅនឹងពាក្យចចាមអារ៉ាម ក៏ដូចជាប្រភពព័ត៌មានមិនច្បាស់លាស់។

ហើយភាគច្រើននៃសាក្សីនៅពេលដែលគាត់និយាយ គឺគាត់និយាយថាមន្ត្រីអតីតមន្ត្រី លន់ នល់ត្រូវបានគេយកចេញក្រៅពីតួ -- គឺវាហួសពីតួនាទីរបស់ចុងជាប់ចោទ។ ខ្ញុំគិតថាអ្វីដែលពួកគាត់បានលើកឡើងគឺមិនអាចទុកចិត្តបាន មិនអាចពឹងផ្អែកបាន ជាពិសេសនៅពេលដែលមានការសួរដេញដោលទៅលើសាក្សី នៅពេលដែលសាក្សីនោះ ត្រូវបានកោះហៅមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។

[១១:៣៤:០៩]

ដោយសារតែយើងមិនដឹងអំពីស្ថានភាពនៃចម្លើយជាង១១០ឯកសារ ដែលនឹងត្រូវទទួលរងការចំណាត់ថ្នាក់ហ្នឹង ១១០ឯកសារហ្នឹង គឺថាយើងគិតថាប្រហែលជាមានការកោះហៅឲ្យមានការផ្តល់សក្ខីកម្មដើម្បីឲ្យយើងធ្វើការសួរដេញដោលទៅលើបញ្ហាទាំងអស់នេះឡើងវិញ។ គឺថានៅក្នុងទឡ្ហីករណ៍របស់យើងៗបានលើកបង្ហាញអំពីសាក្សីមួយចំនួនដែលបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងមានការសួរដេញដោល ហើយនិងលទ្ធផលនៃការសួរដេញដោលដែលយើងបានធ្វើ។

ជាការពិតទៅហេតុផលដែលយើងបានលើកឡើងកាលពីព្រឹកមិញហ្នឹង នៅពេលដែលព្រះរាជអាជ្ញា គាត់ស្នើសុំឲ្យមានសាក្សីបន្ថែមទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ គឺថាវាដូចគ្នាទៅនឹងចំណុចដែលយើងចង់ធ្វើផងដែរ។

ឥឡូវនេះខ្ញុំមិនចង់និយាយលម្អិតថា ហេតុអ្វីបានជាយើងជំទាស់ទៅលើការទទួលយកឯកសារនៃការកំណត់ហេតុស្តាប់ចម្លើយសាក្សីរួចនោះទេ។ ប៉ុន្តែនៅពេលដែលអង្គជំនុំជម្រះសម្រេចថាទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានប្រហែលជា ១០៥ ទៅ១១០ កំណត់ហេតុនោះ នៅពេលនោះគឺថាវាជាការសំខាន់ដែលថា មេធាវីការពារក្តីអាចនឹងមានលទ្ធភាពធ្វើការពិនិត្យសួរដេញដោលទៅលើសាក្សីក៏ដូចទៅលើឯកសារដែលសាក្សីនៃឯកសារនោះត្រូវបានកោះហៅមកបង្ហាញខ្លួននៅចំពោះអង្គជំនុំជម្រះទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ ក៏ដូចជាគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ។

[១១:៣៥:៥១]

ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយថា យើងបានកំណត់នូវបញ្ជីសាក្សីសកត្តានុពលដែលអាច

បង្ហាញអំពីគោលនយោបាយដែលរងការចោទប្រកាន់ថា មានការផ្តោតសំដៅទៅលើមន្ត្រី និងទាហាន លន់ នល់ នោះ គឺខ្ញុំស្នើសុំថា គឺខ្ញុំសូមលើកឡើងថា ភស្តុតាងហ្នឹង គឺដូចជាមិនអាចទុកចិត្តបានទាល់តែសោះ។ ដូច្នេះហើយយើងសង្ឃឹមថានឹងមានការសួរដេញដោលបន្ថែមពីភាគីយើង។

ចំណុចមួយទៀតចុងក្រោយដែលទាក់ទងទៅនឹងសំណើរបស់យើងខ្ញុំ គឺថាយើងខ្ញុំគួរតែរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ១១០ចម្លើយនេះសិន។ ប៉ុន្តែយើងនៅពេលនេះយើងមិនទាន់ប្រាកដថា តើអង្គជំនុំជម្រះសម្រេចយ៉ាងដូចម្តេចនោះទេ។

[១១:៣៦:៥៣]

ហេតុដូច្នេះ ខ្ញុំអាចនិយាយបានថា សំណើរបស់យើងហាក់ដូចជាឆាប់រហ័សបន្តិច ប៉ុន្តែនៅពេលដែលអង្គជំនុំជម្រះសម្រេចថា ទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីណាមួយនោះ គឺថាពេលនោះយើងនឹងមានពេលវេលាបន្ថែមតទៅទៀត។ ហើយយើងនឹងអាចធ្វើសំណើបន្ថែមថ្មីមួយ គឺជាសំណើថ្មីនៅពេលដែលបន្ទាន់មានការ -- នៅពេលដែលមានការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីហ្នឹងរួចទៅហើយ។ ខ្ញុំគិតថា នេះគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់ទាក់ទងទៅនឹងសំណើរបស់ខ្ញុំ ហើយខ្ញុំនឹងរីករាយឆ្លើយតបទៅនឹងការសង្កេតរបស់ភាគីនានា ទាក់ទងទៅនឹងសំណើរបស់យើងខ្ញុំ។

សូមអរគុណលោកប្រធាន។

[១១:៣៧:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះភាគីតំណាងសហព្រះរាជអាជ្ញា សូមអញ្ជើញបាទ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងពាក្យចុងក្រោយរបស់មេធាវីការពារក្តីដែលនិយាយថា ខ្លួនគួរតែរង់ចាំ មុននឹងដាក់សំណើ ហើយខ្លួនបានដាក់នូវសំណើហ្នឹង គឺថាមុនពេលដែលមានការ -- គឺថាការតាំង -- គឺម្សិលមិញប្រហែលជាម៉ោងបួនពេលរសៀល ហើយយើងទទួលបានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ហើយក្នុងពេលដែលអង្គជំនុំជម្រះកំពុងតែរង់ចាំសាក្សី ១១០សាក្សី គឺមិនមែនសំណើសុំសាក្សីមួយពីរទេ គឺសំណើ គឺសាក្សី១១០សាក្សីឯណោះ។ ដូច្នេះហើយខ្ញុំគិតថា នេះមិនមែនជាបញ្ហាដែលយើងនិយាយថា វាឆាប់រហ័សនោះទេ វាជាភាពយឺតយ៉ាវមួយ គឺថាជាបញ្ហាមួយដែលមេធាវីការពារក្តីគួរតែដឹងតាំងពីយូរណាស់មកហើយក្នុងពេលដែលគិតថា អង្គជំនុំជម្រះ

គួរតែកោះហៅសាក្សីមួយចំនួន ឬក៏សាក្សីទាំងអស់ ព័ត៌មានហ្នឹងគឺថាមានតាំងយូរណាស់មកហើយ។

[១១:៣៩:០៧]

នៅមានបញ្ហាច្រើនទៀតដែលសារណានេះបានលើកឡើង ពាក់ព័ន្ធទៅនឹងការពឹងផ្អែករបស់តុលាការទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលគិតថា វាខុស ឬក៏វាមិនត្រឹមត្រូវទៅនឹងតាម -- ការពិតទៅគឺថាការលើកឡើងអំពីភស្តុតាងដែលបង្ហាញអំពីគោលនយោបាយនុ៎ះ គឺថាសំណើហ្នឹង គឺយើងបានទទួលនៅម៉ោងបួនរសៀលកាលពីម្សិលមិញ។ ដូច្នេះយើងស្នើសុំឲ្យមានពេលវេលាដើម្បីឲ្យយើងដាក់នូវចម្លើយតបជាលាយលក្ខណ៍អក្សរចំពោះសំណើនេះ។ ទោះបីយ៉ាងណាក៏ដោយក្នុងពេលខ្ញុំសូមលើកឡើងនូវមតិមួយចំនួនពាក់ព័ន្ធទៅនឹងអ្វីដែលបានស្នើហ្នឹង ទោះបីថាយើងមានពេលវេលាតិចតួចក៏ដោយ។

ចំណុចទី១ ខ្ញុំសូមធ្វើការកត់សម្គាល់ថា មេធាវីការពារក្តីមានកំហុសឆ្គងចំពោះបញ្ហានៅក្នុងសំណើនេះ។ មេធាវីការពារក្តីផ្តោតតែទៅលើគោលនយោបាយសម្លាប់។ គឺគោលនយោបាយសម្លាប់ទាហាន និងមន្ត្រីរបបអតីតខ្មែរសាធារណរដ្ឋ។ ហើយខ្ញុំសូមជម្រាបដល់មេធាវីកាពារក្តី ក៏ដូចជាអង្គជំនុំជម្រះថាគោលនយោបាយ ហើយនិងបញ្ហាដែលលើកឡើងនៅទីនេះ គឺវាធំជាងនេះទៅទៀត។ គឺគោលនយោបាយដែលផ្តោតទៅលើមនុស្សនៅក្នុងក្រុមនេះ ក៏ដូចជាឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ គឺមិនមែនត្រឹមតែមនុស្សឃាតនោះទេ។ គឺជាការធ្វើទុក្ខបុកម្នេញ -- គឺការសម្លាប់ដោយផ្អែកទៅលើមូលដ្ឋាននយោបាយ។

[១១:៤០:៥០]

ដូច្នេះ នៅពេលដែលមេធាវីការពារក្តីបដិសេធ ឬក៏ច្រានចោលនូវភស្តុតាងមួយចំនួនដែរថាបុគ្គលទាំងអស់នេះ ត្រូវបានគេបែងចែក ត្រូវបានគេរើសអើង ហើយត្រូវបានគេបញ្ជូនទៅកន្លែងរៀនសូត្រ គឺថាមេធាវីការពារក្តីកំពុងតែធ្វើឲ្យអង្គជំនុំជម្រះ ក៏ដូចជាសាធារណជនយល់ច្រឡំ។ ដូច្នេះគឺថាជនជាប់ចោទគួរតែទទួលការចោទប្រកាន់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត។

ខ្ញុំសូមដកស្រង់នូវកថាខណ្ឌ១៤១៦ ដល់១៤១៧ ទាក់ទងទៅនឹងការសម្លាប់ដោយផ្អែកទៅលើមូលដ្ឋានគោលនយោបាយ។

ចំណុចទី២ ដែលខ្ញុំចង់លើកផងដែរ គឺមានលើកឡើងខុស ក៏ដូចជាការលើកឡើងមិនត្រឹមត្រូវនៅក្នុងសំណើផងនោះផងដែរ ហើយខ្ញុំគិតថាប្រហែលជាចេតនារបស់មេធាវីការពារក្តីក្នុងលើកសេចក្តី

សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

ដូច្នេះ ខ្ញុំមិនពិភាក្សាអំពីបញ្ហានៅថ្ងៃនេះទេ។ ប៉ុន្តែដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំសូមលើកឡើងថា ផ្នែកមួយចំនួនដែលបានលើកឡើងនៅក្នុងសំណើសុំនុំង គឺថាហាក់ដូច -- និយាយថា វាហាក់ដូចជាវាមិនមានភស្តុតាងណាមួយទាក់ទងទៅនឹងគោលនយោបាយហ្នឹង គឺថាយើងសូមជំទាស់យ៉ាងខ្លាំងចំពោះការកំណត់អត្តសញ្ញាណរបស់មេធាវីការពារក្តី ទាក់ទងទៅនឹងសក្ខីកម្មហ្នឹង ក៏យើងសូមជំទាស់ផងដែរ។

[១១:៤២:២៨]

ខ្ញុំសូមលើកឧទាហរណ៍មួយ មេធាវីការពារក្តីបានបញ្ជាក់ថា សក្ខីកម្មរបស់ មាស វឿន ហាក់ដូចជាមិនបានគាំទ្រទៅដល់គោលនយោបាយដែលថាផ្តោតទៅលើមន្ត្រី និងទាហានខ្មែរសាធារណរដ្ឋ។ ដូច្នេះហើយគឺថាលោក មាស វឿន ដែលជាអនុបញ្ជាការនៃកងទ័ពប្រចាំនៅភូមិភាគបស្ចិម គឺបានបញ្ជាក់រួចទៅហើយថា គ្មានការត្រួតពិនិត្យទៅលើប្រវត្តិរូប ក៏ដូចជាការធ្វើបោសសម្អាតបុគ្គលដែលមានទំនាក់ទំនងជាមួយនឹងអតីតរបបចាស់។ នេះគឺជាសក្ខីកម្មរបស់ មាស វឿន។

មេធាវីការពារក្តីបានផ្តល់បញ្ជី ហើយទទួលស្គាល់ថាមានសាក្សី២១ ឬក៏មានដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងទៅនឹងបញ្ហានេះ។ ដូច្នេះ តុលាការបានស្តាប់នូវសក្ខីកម្មយ៉ាងច្រើន ហើយខ្ញុំសូមកត់សម្គាល់ផងដែរថា វាមានព័ត៌មានលម្អិតយ៉ាងច្រើនដែលមេធាវីការពារក្តីមិនបានដាក់បញ្ចូលទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សីមួយចំនួន ដូចជា រ៉ូកូហ្វ, ហ្វីលីព ស្សូត, ស៊ីដនី ស្កេនប៊ឺជ ហើយនិងសំខាន់បំផុតគឺសក្ខីកម្មរបស់សាក្សី ឌុច ដែលជាប្រធានមន្ទីរ ស-២១។ ដែល ឌុច គាត់បានផ្តល់សក្ខីកម្មផងដែរថា ក្រុមជនរងគ្រោះទី១ ដែលផ្តោតគោលដៅនៅក្នុងពេលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺក្រុមទាំងអស់នេះ។ គឺក្រុមមនុស្សដែលពាក់ព័ន្ធទៅនឹងរបបសាធារណរដ្ឋខ្មែរ។

[១១:៤៤:១៧]

ដូច្នេះ យើងមានបញ្ហាជាមួយនឹងការកំណត់ប្រភេទ ក៏ដូចជាការលើកឡើងនៅក្នុងសារណានេះផងដែរ។ ហើយយើងខ្ញុំសូមស្នើថានឹងដាក់នូវសារណាជាលាយលក្ខណ៍អក្សរនៅពេលក្រោយ ហើយយើងសូមបញ្ជាក់ថា សារណារបស់យើងគឺជាសារណាដែលមានទំហំធំ ហើយវាមានច្រើនទំព័រ។ អានេះគឺអ្វីដែលខ្ញុំចង់លើកឡើងពេលនេះ គឺថាបន្ទាប់ពីខ្ញុំបានមើលសារណាសំណើដែលខ្ញុំបានទទួល

កាលពីម្សិលមិញនៅម៉ោងបួនរសៀល។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយខ្លីទេ យើងគាំទ្រសហព្រះរាជអាជ្ញាចំពោះសំណើដែលខាងការពារក្ដីសុំពេលចុងក្រោយនេះ ហើយនិងសុំឱ្យស្ដាប់១១០នាក់ទៀតនេះ។ អ៊ីចឹងការសុំនេះគ្រាន់តែការអូសបន្លាយពេលវេលាប៉ុណ្ណោះទេ។ អ៊ីចឹងខ្ញុំ សហភាតារបស់ខ្ញុំបាននិយាយថា ភស្ដុតាង -- ភាពចាំបាច់នៃការស្ដាប់សាក្សីទាំងអស់នេះ គឺថាយើងបានដោយសារយើងបានស្ដាប់មួយចំនួនមកហើយ ដោយសារក្នុងចំណោមអ្នកដែលយើងបានស្ដាប់ហើយហ្នឹង សុទ្ធតែមិនអាចទុកចិត្តបាននោះទេ។

ខ្ញុំសូមធ្វើការកត់សម្គាល់ថា នេះជាការយល់ឃើញរបស់គាត់ទេ។ ហើយគាត់អាចនិយាយអ៊ីចេះបាននៅក្នុងសារណាបញ្ចប់ការដេញដោលរបស់គាត់។ ហើយអង្គតុលាការនឹងពិចារណាបើតាមការដែលខ្លួនយល់ឃើញនៅពេលក្រោយ។

ការកត់សម្គាល់មួយទៀតរបស់ខ្ញុំ គឺថានៅពេលដែលសហភាតាខ្ញុំនេះធ្វើសំណើនេះ គឺថាគាត់យើងគិតថាប្រហែលជាគាត់មិនយល់អំពីនីតិវិធី ហើយនិងការសេចក្ដីណែនាំរបស់តុលាការនោះទេ។ អ៊ីចឹងថាប្រហែលរហូតនេះៗ គាត់គិតថាគាត់មិនចាំបាច់យល់ពីសេចក្ដីណែនាំរបស់តុលាការទេ ហើយខ្ញុំគ្រាន់តែចង់ជម្រាបថា កំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីហ្នឹងៗសំខាន់ណាស់របស់សហចៅក្រមស៊ើបអង្កេតហ្នឹង។ អ៊ីចឹងយើងមិនបាច់ស្ដាប់ម្ដងទៀតនៅទីនេះនៅរាល់សាក្សីដែលមេធាវីរបស់ នួន ជា ស្នើសុំនោះទេ។ អ៊ីចឹងសូមឱ្យតុលាការបដិសេធសំណើនេះចោលតែម្ដង។

[១១:៤៦:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាការកត់សម្គាល់ចុងក្រោយវាគួរឱ្យចាប់អារម្មណ៍ គឺថាអ្វីដែលយើងបានធ្វើក្នុងរយៈពេលកន្លងមក គឺក្នុងពេលជាង២ឆ្នាំ គឺថាសាក្សីដែលបានបង្ហាញនូវ បង្ហាញខ្លួននៅទីនេះ គឺមិន -- គឺបានផ្ដល់សក្ខីកម្មរួចទៅហើយនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះគឺថាយើងឥឡូវហ្នឹង

ហាក់ដូចជាកំពុងតែពឹងផ្អែកទៅលើចម្លើយរបស់សាក្សីចំពោះលើបញ្ហាទាំងអស់នេះ។

ខ្ញុំកត់សម្គាល់យ៉ាងសំខាន់ទៅលើការកត់សម្គាល់របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំបញ្ជាក់ថាវាអាចជាភាពយឺត ប៉ុន្តែយ៉ាងណាក៏ដោយដូចខ្ញុំបានបញ្ជាក់ពីមុនរួចមកហើយ ថាឯកសារទាំងអស់នេះគឺឯកសារដែលយើងបាននិយាយយោងនៅក្នុងឯកសារភ្ជាប់របស់យើង គឺមិនទាន់បានបញ្ជាក់រួចទៅហើយៗអង្គជំនុំជម្រះក៏មិនទាន់បានទទួលនូវចម្លើយរបស់សាក្សីទាំងអស់នេះផងដែរ។

[១១:៤៧:៥៩]

ដូច្នេះគឺថាខ្ញុំមិនមែនចង់មានន័យថា ជាការណែនាំអីអ្វីចំពោះអង្គជំនុំជម្រះនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែសង្ឃឹមថានឹងមានការពិចារណាទៅលើឯកសារ។ ប្រសិនបើអង្គជំនុំជម្រះបានសម្រេចរួចទៅហើយនោះ គឺថាដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ គឺថាអ្វីដែលយើងអាចធ្វើបាននៅពេលដំបូងនោះ គឺយើងនឹងដាក់សំណើមួយ ដើម្បីធ្វើការកោះហៅសាក្សីហ្នឹងមកសួរដេញដោល គឺថាបន្ទាប់ពីការមានទទួលយកឯកសារទាំងអស់នេះ។

ដូច្នេះខ្ញុំសូមបញ្ជាក់ឡើងវិញថា យើងហាក់ដូចជាឆាប់រហ័សបន្តិច ព្រោះឯកសារ ក៏ដូចជាចម្លើយសាក្សីទាំងអស់នោះមិនទាន់បានទទួលយកជាភស្តុតាងនៅឡើយ។ ក្នុងពេលឥឡូវនេះ គឺមិនទាន់ជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ នៅឡើយនៅពេលឥឡូវនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចំពោះសំណើនេះ អង្គជំនុំជម្រះនឹងយកទៅសម្រេចជាផ្នែកមួយនៃសេចក្ដីសម្រេចអំពីការស្ដីពីកំណត់ហេតុយកចម្លើយសាក្សី ដែលសេចក្ដីសម្រេចនេះអង្គជំនុំជម្រះបញ្ជាក់នៅពេលចុងក្រោយនៃថ្ងៃសវនាការថ្ងៃនេះ។ ហើយដោយសារតែសំណើនេះត្រូវបានឆ្លើយតបដោយផ្ទាល់មាត់រួចហើយ ដូច្នេះអង្គជំនុំជម្រះមិនតម្រូវឲ្យភាគីននានាដាក់សារណាជាលាយលក្ខណ៍អក្សរទៀតទេ។

[១១:៤៩:២៦]

បាទជាបន្តទៅនេះអង្គជំនុំជម្រះសូមផ្ដល់ -- អង្គជំនុំជម្រះសូមលើកឡើងនូវសំណើមួយរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលបានស្នើសុំព័ត៌មានទាក់ទងទៅនឹងលក្ខខណ្ឌនៃការកោះហៅលោក នូ មោក ឲ្យចូលខ្លួននៅចំពោះមុខតុលាការកាលពីម្សិលមិញ។ ហើយអង្គជំនុំជម្រះក៏សូមអញ្ជើញភាគីដទៃទៀតឆ្លើយតប ដោយចាប់ផ្ដើមពីមេធាវីការពារក្ដី នួន ជា ផងដែរ។

អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ខៀវ សំផន!

សូមអញ្ជើញលោកៗក្រុមមេធាវីការពារក្ដីលោក នួន ជា មុនបាទ ប្រសិនបើមានបំណងបញ្ជាក់លើបញ្ហានេះ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំមិនប្រាកថាតើខ្ញុំត្រូវឆ្លើយតបទៅនឹងអ្វីនោះទេ។ ខ្ញុំស្ដាប់អត់ទាន់អ្វីដែលលោកប្រធានមានប្រសាសន៍អម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

កាលពីម្សិលមិញ អង្គជំនុំជម្រះបានទទួលនូវសំណើសុំមួយរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែលស្នើសុំផ្ដល់ព័ត៌មានទាក់ទងទៅនឹងលក្ខខណ្ឌនៃការកោះហៅលោក នូ មោក ឱ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ ហើយសំណើនេះដាក់កាលពីម្សិលមិញ។ ហើយនាពេលនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅភាគពាក់ព័ន្ធដទៃទៀតដើម្បីមានឱកាសក្នុងការបញ្ចេញមតិយោល់ ឬក៏ឆ្លើយតបទៅនឹងសំណើសុំនេះ។ ហើយដោយសារសំណើនេះ វាជាសំណើម្ខាងរបស់ភាគីខាងមេធាវីដូច្នេះគប្បីឱ្យក្រុមមេធាវីការពារក្ដីហ្នឹងអាចលើកឡើងនូវមតិយោបល់របស់ខ្លួន បើសិនបើមានបំណងធ្វើដូច្នេះ។ បើមិនមានបំណងគឺគ្រាន់តែបញ្ជាក់ថាមិនមានទៅ អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅភាគីម្ខាងទៀត ដើម្បីឱ្យដំណើរការហ្នឹងវាលឿន។ ចៀសវាងអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅភាគីម្ខាងទៀត ហើយភាគីរបស់លោកលើកឡើងថាអះអាងយ៉ាងហោចណាស់ក៏បង្ហាញពីជំហរគាំទ្រ។

សូមអញ្ជើញ!

[១១:៥២:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ហើយលោកប្រធាន។ សូមអរគុណ គឺថាខាងមេធាវីខ្ញុំមិនមានអ្វីលើកឡើងទេនៅពេលឥឡូវនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅភាគីតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយសង្ខេបទាក់ទងទៅនឹងសារណាមួយនេះ។ គឺថាសារណាដែលខ្ញុំបានទទួលកាលពីម្សិលមិញពេលរសៀលផងដែរ។ សារណានេះបានស្នើសុំដល់

អង្គជំនុំជម្រះឲ្យធ្វើការស៊ើបអង្កេតបន្ថែមពាក់ព័ន្ធទៅនឹងកាលៈទេសៈដែលសាក្សី នូ មោក ត្រូវបានគេផ្តល់ឲ្យនូវរូបថតរបស់លោ ប៉ែន ឃៀរនិន ហើយនិងផ្តល់នូវកំណត់ត្រានៃការសម្ភាសរបស់គាត់ជាមួយ ប៉ែន ឃៀរនិន កាលពីលើកមុន។

ដូច្នេះ ខ្ញុំចង់លើកឡើងថា វាមិនមានលក្ខខណ្ឌ ឬក៏មិនមានភាពចាំបាច់ដែលតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែមនោះទេ។ ហើយអង្គជំនុំជម្រះខ្លួនឯងក៏បានបញ្ជាក់ផងដែរនៅក្នុងពេលផ្តល់សក្ខីកម្មថាការផ្តល់រូបថត ប៉ែន ឃៀរនិន គឺថាត្រូវបានប្រើប្រាស់ដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីបញ្ជាក់ច្បាស់ថា សាក្សីដែល -- ដើម្បីបញ្ជាក់ថាសាក្សីដែលខ្លួនចង់រកហ្នឹង គឺជាសាក្សីត្រឹមត្រូវ។ ហើយចំពោះការផ្តល់ឯកសារនៃការសម្ភាស ខ្ញុំគិតថាវាដូចជាមិនមានបង្កផលប៉ះពាល់ ឬក៏ព្យសនកម្មអ្វីនោះទេ នៅពេលដែលសាក្សីគាត់អាចពិនិត្យមើលទៅលើកំណត់ត្រានៃការសម្ភាសរបស់គាត់។

ដូច្នេះ ខ្ញុំគិតថាវាជាឱកាសដ៏ត្រឹមត្រូវដើម្បីឲ្យសាក្សីគាត់អាចផ្តល់សក្ខីកម្ម ហើយគាត់មានឱកាសពិនិត្យមើលទៅលើឯកសារដែលគាត់នឹងត្រូវបានគេសួរដេញដោល។

[១១:៥៤:00]

សាក្សីរូបនេះបានធ្វើការកែសម្រួល ឬក៏នៅពេលដែលគាត់គិតថាកំណត់ហេតុសម្ភាសហ្នឹងគឺមិនត្រឹមត្រូវ គាត់តែងតែជម្រាបទៅដល់អង្គជំនុំជម្រះ។ ដូច្នេះខ្ញុំយល់ឃើញថាហាក់ដូចជាគ្មានហេតុផលអ្វីដែលអង្គជំនុំជម្រះត្រូវធ្វើការស៊ើបសួរ ឬក៏ស៊ើបអង្កេតទៅលើបញ្ហាទាំងអស់នេះទេ។ ហេតុដូច្នេះខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះច្រានចោលនូវសំណើរបស់មេធាវីការពារក្តីរូបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ ហើយនិងសាធារណជន។ ខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏យល់ឃើញថាមិនមានភាពចាំបាច់នៅក្នុងការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៅក្នុងការផ្តល់ឯកសារទៅសាក្សី នូ មោក នេះដែរ ហើយដូចតំណាងសហព្រះរាជអាជ្ញាដែរ គឺមិនឯកភាពចំពោះការស្នើសុំថាមិនទទួលយកសំណើរបស់តំណាង មេធាវីរបស់លោក ខៀវ សំផន នេះទេបាទ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនិយាយដោយខ្លីទេលោកប្រធាន។ តុលាការដឹងហើយចាំហើយគឺថានៅពេលដែលលោក នូ មោក នេះមកផ្តល់សក្ខីកម្ម កាលនោះខ្ញុំបាននិយាយខ្ញុំសួរគាត់ កាលនោះសួរសំណួរទៅគាត់គឺមានចំណុចពីរចង់ដឹងថា តើរូបថតនោះត្រូវបានផ្តល់ជូនទៅសាក្សីនេះក្នុងលក្ខខណ្ឌណា? ហើយចំណុច ទី២ គឺថា គាត់បានមើលពិគ្រោះកំណត់ត្រារបស់ ប៉ែន យៀវនិន នៅពេលណាដែរ?

[១១:៥៦:០៨]

ទាក់ទងទៅនឹង ចំណុចទី១តុលាការកត់សម្គាល់ឃើញហើយថាវាមិនមែនតែចង់បានចម្លើយពីតុលាការថាតើរូបថតនោះត្រូវបានបង្ហាញជូនទៅគាត់ដើម្បីកំណត់សម្គាល់អត្តសញ្ញាណរបស់គាត់ដែរឬទេ គឺថាសំណើរបស់យើងជាក់លាក់ជាងនេះគឺយើងចង់ដឹងថាតើរូបថតនេះត្រូវបានផ្តល់ជូនគាត់នៅពេលណា? ក្នុងកាលៈទេសៈណា? តើនៅក្នុងពេលបង្ហាញទៅភ្លាមនោះ គាត់ស្គាល់ភ្លាមនោះ ឬក៏យ៉ាងម៉េច? ចំណុចនេះសំខាន់ណាស់ យើងសូមរំឭកថា នៅក្នុង -- នៅលើរូបថតនោះមានសរសេរឈ្មោះ ប៉ែន យៀវនិន។

នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់យើងមានសរសេរអស់ហើយ។ យើងខ្ញុំមិននិយាយវែងឆ្ងាយទេ ពីព្រោះថាលក្ខខណ្ឌនៃការផ្តល់រូបថតឲ្យគាត់នេះសំខាន់ណាស់។ ហើយយើង ឥឡូវនេះយើងសុំព័ត៌មានបន្ថែម គឺចង់ដឹងថា តើនៅក្នុងកម្រិតណានៅក្នុងលក្ខខណ្ឌណាដែលសក្ខីកម្មរបស់គាត់នោះត្រូវទទួលឥទ្ធិពលពីកន្លែងណាមួយ។

ហើយចំណុចទី២គឺកំណត់ត្រារបស់ ប៉ែន យៀវនិន ហើយអង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពីមុននោះ ច្បាស់ហើយគឺថា យើងមិនចាំបាច់ផ្តល់ចម្លើយមួយដែលថាមានចុះហត្ថលេខារបស់សាក្សីនោះទេ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា មានកំណត់សម្គាល់ដែលមិនមែនជារបស់គាត់។ ហើយយើងនឹងនិយាយនៅក្នុងសារណារបស់យើងមានការសរសេរមួយចំនួន ដែលខុសគ្នាពីពេលវេលានៃកិច្ចសម្ភាសន៍ ហើយនិងដោយអត់មានសំណួរច្បាស់លាស់ជាដើមរបស់អ្នកដែលសម្ភាសគាត់ហ្នឹង។

អ៊ីចឹងពុំមានភាគីទាំងអស់នោះមិនអាចយល់ច្បាស់អំពីពេលវេលាណាដែលថាគេសួរសុំព័ត៌មានអីមួយទៅសាក្សី ហើយពេលណាដែលសាក្សីហ្នឹងត្រូវបានគេនាំមុខ។ អ៊ីចឹងនេះជាបញ្ហាសំខាន់ណាស់

យើងមិនអាចយកកំណត់ត្រារបស់អ្នកណាម្នាក់ ហើយនិងមកច្រឡូកច្របល់គ្នាជាមួយនឹងកំណត់ត្រាផ្ទាល់របស់សាក្សីនោះទេ។

[១១:៥៩:១៧]

អ៊ីចឹងខ្ញុំចង់ដឹងថាតើក្នុងកាលៈទេសៈណាដែលគេផ្តល់កំណត់ត្រារបស់ បែន យៀវនិន ជូនទៅសាក្សី? អ៊ីចឹងតើគេផ្តល់ឲ្យមុនពេលដែលគាត់មកផ្តល់សក្ខីកម្មនៅទីនេះ ឬក៏យ៉ាងម៉េច? ហើយមានហត្ថលេខាអីជាដើមនេះ អ៊ីចឹងចំណុចនេះសំខាន់ណាស់។ មានការជំទាស់នៅតុលាការយើងនេះនៅពេលដែលគាត់មកផ្តល់សក្ខីកម្មនោះ ចង់ដឹងថាតើគាត់ហ្នឹងចងចាំច្បាស់លាស់ដែរឬទេ? ឬក៏ខុសពីចម្លើយពីមុនៗរបស់គាត់? មានសួរផងដែរថាតើកំណត់ត្រារបស់គាត់នោះមិនដូចនឹងចម្លើយដែលគាត់ផ្តល់ជូនទៅសហចៅក្រមស៊ើបអង្កេតនោះទេ?

អ៊ីចឹងគឺថាមានបញ្ហានេះច្រើន ហើយបញ្ហាពាក់ព័ន្ធទៅនឹងតម្លៃភស្តុតាងផងដែរ ដោយសារសក្ខីកម្មរបស់គាត់នោះមានទទួលឥទ្ធិពលពីខាងក្រៅ។ អ៊ីចឹងការកត់សម្គាល់របស់ខ្ញុំនៅត្រឹមប៉ុណ្ណេះឯង។ ហើយខ្ញុំនឹងនិយាយលម្អិតនៅក្នុងសារណារបស់ខ្ញុំនៅពេលក្រោយ។ ខ្ញុំសូមឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ដែលគាត់លើកឡើងថា គេមានសិទ្ធិផ្តល់ជាកំណត់ត្រាទៅសាក្សី។ ហើយអ៊ីចឹងខ្ញុំសូមជំទាស់កន្លែងនេះដែលមិនជាការត្រឹមត្រូវទេ។

[១១:៥៩:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីផងដែរថា នៅរសៀលនេះ អង្គជំនុំជម្រះនឹងមានលទ្ធភាពក្នុងការចេញសេចក្តីសម្រេចផ្ទាល់មាត់ លើបញ្ហាដែលជាប្រធានបទនៃការជជែកពិភាក្សាកន្លងមកនេះ ឬនិងបញ្ហាមួយចំនួនផ្សេងទៀតដែលមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿងក្តី ហើយក៏អាចនឹងបញ្ជាក់អំពីកាលវិភាគនៃការកំណត់រយៈពេលនៃកាលបរិច្ឆេទចុងក្រោយផងដែរ ប្រសិនបើខ្លួនយល់ឃើញថាសមស្រប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមដែលនៅក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់

សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៥:០៧នាទី)*

[១៥:០៧:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

បន្ទាប់ពីសារណាររបស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់ភាគីនានា ឥឡូវនេះអង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើមួយចំនួនរបស់ភាគី សំអាងហេតុពេញលេញនៃសេចក្ដីសម្រេចនេះនឹងមាននៅក្នុងសេចក្ដីសម្រេច ស្ដីពីការជំទាស់ទៅនឹងភាពទទួលយកបាននៃកំណត់ហេតុស្ដាប់សក្ខីកម្មសាក្សី ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងត្រូវចេញឆាប់នាពេលខាងមុខ និងសេចក្ដីសម្រេចចុងក្រោយអំពីសាក្សី។

[១៥:០៨:៥៥]

សំណើរបស់សហព្រះរាជអាជ្ញា សូមឲ្យអង្គជំនុំជម្រះសាលាដំបូងស្ដាប់សក្ខីកម្មសាក្សីទួលពោធិ៍ជ្រៃបន្ថែម។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីបន្ថែមចំនួនពីររូប ទាក់ទងនឹងទួលពោធិ៍ជ្រៃ គឺ TCW-440 -- 644 និងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤។

មេធាវីការពារក្ដី នួន ជា មិនជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានេះទេ និងបានស្នើសុំបន្ថែមឲ្យអង្គជំនុំជម្រះកោះហៅសាក្សី TCW-802, TCW-803 និងលោក រ៉ប់ លឹមគិន*(Rob Lemkin)*។

អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងរបស់សាក្សី TCW-644, TCW-802, TCW-803 និងដើមបណ្ដឹងរដ្ឋប្បវេណីថ្មីនេះមានលក្ខណៈច្រំដែលទៅនឹងភស្តុតាងដទៃ និងមិនបាននាំដល់ការស្វែងរក

ការពិតទេ។ ហេតុដូច្នេះសំណើទាំងនេះត្រូវបដិសេធចោល។

សំណើសុំឲ្យកោះហៅលោក រ៉ប់ លឹមគិន ត្រូវបានសម្រេចនៅក្នុងសេចក្តីសម្រេចដោយឡែក ដែលនឹងចេញនៅក្នុងពេលឆាប់ៗខាងមុខនេះ។

អំពីសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញលើសេចក្តីសម្រេចមិនកោះហៅ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ឯកសារ E293/1។

ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន មិនកោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី ស សារិន។ បើទោះបីជាសំណើនេះត្រូវបានចាត់ទុកថាជាសំណើថ្មីក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនបានបង្ហាញនូវកាលៈទេសៈថ្មីឡើយ។

[១៥:១១:២៣]

អង្គជំនុំជម្រះក៏មិនមានឃើញលក្ខខណ្ឌនៃវិធាន៣៥ ត្រូវបានបំពេញឡើយ។ ហេតុដូច្នេះសំណើរបស់សហព្រះរាជអាជ្ញា ឯកសារ E293/1 ត្រូវច្រានចោល។

អំពីសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលបានស្នើសុំឲ្យកោះហៅសាក្សីដែលពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់ក្នុងការវាយប្រហារមន្ត្រីសាធារណរដ្ឋខ្មែរ។ សំណើក្រៅផ្លូវការ។ មេធាវី នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីថ្មីជាង១០០នាក់ ដែលបានឆ្លើយនៅក្នុងកំណត់ហេតុយកចម្លើយទាក់ទងនឹងការវាយប្រហារលើមន្ត្រីសាធារណរដ្ឋខ្មែរ។ សំណើនេះនិយាយច្រំដែល និងបានកែលម្អលើសំណើលើកមុនៗទាក់ទងនឹងភាពទទួលយកបាន មិនមានឱកាសសម្រាប់តទល់ទៅនឹងសេចក្តីថ្លែងការណ៍ ទាក់ទងនឹងបញ្ហាសំខាន់ទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញា។

អង្គជំនុំជម្រះយល់ឃើញថា សំណើរបស់មេធាវីការពារក្តីខកខាន មិនបានបំពេញលក្ខខណ្ឌសមហេតុផលក្នុងការបង្ហាញអំពីការរកឃើញសាក្សីថ្មីដែលត្រូវស្នើសុំកោះហៅឲ្យស្របតាមវិធាន៨៧ អនុវិធាន៤នោះឡើយ។

[១៥:១២:៥៦]

លើសពីនេះទៅទៀត ចំពោះសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឆ្លើយតបចំពោះសំណើនេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ហានេះទាក់ទងទៅនឹងភាពទទួលយកបាន និងតម្លៃនៃកំណត់ហេតុ

យកចម្លើយសាក្សីដែលត្រូវបានថ្លែងដោយសង្ខេបសព្វគ្រប់ហើយ។ ហើយអង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចលើបញ្ហានេះនាពេលឆាប់ៗខាងមុខនេះ។

សំណើដទៃទៀតនាពេលខាងមុខស្ដីពីបញ្ហាទាំងនេះនឹងត្រូវចាត់ទុកថាច្រំដែល និងមិនទទួលយកបានឡើយ។ សំណើផ្ទាល់មាត់នេះត្រូវច្រានចោលដែលសំអាងហេតុលម្អិតនឹងមានចេញជាក្រោយ។

អំពីសំណើរបស់មេធាវីខៀវ សំផន អំពីព័ត៌មានទាក់ទងទៅនឹងលោក នូ មោក។ ជាបឋមអង្គជំនុំជម្រះកត់សម្គាល់ថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ត្រូវបានសន្មត់ថាបំពេញមុខងាររបស់ខ្លួនដោយមិនលម្អៀង។ ភាគីនានាមានឱកាសស្រាវជ្រាវបញ្ហានានា ទាក់ទងទៅនឹងការធ្វើទំនាក់ជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងអំឡុងពេលសួរសាក្សីរូបនោះ។

[១៥:១៤:២៨]

លើសពីនេះទៅទៀត អង្គជំនុំជម្រះក៏បានទទួលនូវព័ត៌មានពាក់ព័ន្ធក្រៅផ្លូវការពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញហើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសន្និដ្ឋានថាការស៊ើបអង្កេតស្របតាមវិធាន៣៥ត្រូវច្រានចោល។ ប៉ុន្តែអង្គជំនុំជម្រះបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញផ្ដល់នូវព័ត៌មាននេះជាលាយលក្ខណ៍អក្សរផ្លូវការមកអង្គជំនុំជម្រះក្នុងរយៈពេល២សប្ដាហ៍។

ឥឡូវនេះ អង្គជំនុំជម្រះសូមចូលទៅសំណើរបស់សហព្រះរាជអាជ្ញាដែលធ្វើឡើងដោយផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរនៅក្នុងឯកសារ E288/4/1 ពាក់ព័ន្ធនឹងការបដិសេធរបស់ជនជាប់ចោទមិនឆ្លើយទៅនឹងសំណួរនានា។ អង្គជំនុំជម្រះពិចារណាឃើញថា ការរំឭកដែលបានធ្វើចំពោះជនជាប់ចោទទាំងអស់ កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ និងការបញ្ជាក់សាជាថ្មីឡើងវិញ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ គឺបានដោះស្រាយយ៉ាងគ្រប់គ្រាន់ចំពោះចំណុចសំខាន់នៅក្នុងសំណើជាសារធាតុរបស់សហព្រះរាជអាជ្ញាហើយ។ ការរំឭកអំពីកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ បានបញ្ជាក់ដោយយោងទៅរកយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធថា ការសម្រេចជ្រើសរើសដោយខ្លួនឯង ក្នុងការនៅស្ងៀមមិនឆ្លើយតបអាចត្រូវបានប្រើក្នុងការទាញចេញជាសេចក្ដីសន្និដ្ឋានផ្ទុយ។

[១៥:១៦:១៩]

ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថា សំណើទាំងអស់នេះត្រូវបានឆ្លើយតបរួចរាល់អស់ហើយ។

សហព្រះរាជអាជ្ញាបានស្នើសុំបន្ថែមដើម្បីថ្លែងនៅក្នុងសវនាការ ដោយមានវត្តមានរបស់ជនជាប់ចោទអំពីប្រធានបទ និងអង្គហេតុដែលខ្លួនចង់ចោទសួរទៅជនជាប់ចោទ។

អង្គជំនុំជម្រះពិចារណាឃើញថា សំណើនេះមិនមែនជាការចាំបាច់នោះទេ។ សហព្រះរាជអាជ្ញានឹងមានឱកាសសរសេរជាផ្នែកមួយនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នៅបណ្តារចំណុចទាំងឡាយដែលខ្លួនបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការទាញសេចក្តីសន្និដ្ឋានផ្ទុយនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះនឹងដោះស្រាយនូវសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានស្នើសុំដាក់ឯកសារថ្មី។ ស្នើសុំអង្គជំនុំជម្រះកោះហៅ លោក រ៉ប់ លឹមគិន ធ្វើជាសាក្សី ព្រមទាំងស្នើសុំឱ្យមានកិច្ចស៊ើបអង្កេតផងដែរ។

អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចរបស់ខ្លួន ដាក់ចូលនៅក្នុងសំណុំរឿងនៅថ្ងៃនេះ ឬថ្ងៃស្អែកដោយសម្រេចបដិសេធលើស្នើសុំទាំងនេះ លើសំណើសុំនេះទាំងអស់។ ដោយផ្អែកលើសំអាងហេតុដែលមានរៀបរាប់នៅក្នុងសេចក្តីសម្រេចនោះ។

[១៥:១៧:៥០]

ចំពោះសេចក្តីសម្រេចដទៃទៀត អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចចំនួនពីរក្នុងពេលឆាប់ៗដែលរួមមាន សេចក្តីសម្រេចបដិសេធភាពអាចទទួលបាននៃកំណត់ហេតុស្តាប់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ និងសេចក្តីសម្រេចទី៣ ស្តីពីការជំទាស់ទៅនឹងឯកសារដែលបានស្នើឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

សេចក្តីសម្រេចទាំងពីរនេះនឹងមានភ្ជាប់ឧបសម្ព័ន្ធផងដែរ។ ឯកសារទាំងអស់ដែលត្រូវបានទទួលយក ដែលជាលទ្ធផលនៃសេចក្តីសម្រេចនេះ នឹងមានលេខ E3។

ជាចុងក្រោយនេះ អង្គជំនុំជម្រះសូមបញ្ជាក់អំពីការកំណត់កាលបរិច្ឆេទចាប់ពីពេលនេះបន្តទៅមុខទៀត ដូចខាងក្រោមនេះ។

នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ខ្លួន ឯកសារ E284។ អង្គជំនុំជម្រះបានសម្រេចពីវិសាលភាពនៃអង្គហេតុ ដែលអង្គជំនុំជម្រះត្រូវធ្វើការពិចារណានៅក្នុងសំណុំរឿង០០២/០១។ សេចក្តីសម្រេចនេះ ត្រូវបានប្តឹងសាទុក្ខដោយសហព្រះរាជអាជ្ញា និង នួន ជា។ ដោយរង់ចាំលទ្ធផលនៃបណ្តឹងសាទុក្ខ និងដើម្បីជៀសវាងការប៉ះពាល់ដែលអាចមានចំពោះភាគីទាំងអស់។

[១៥:១៩:២៩]

អង្គជំនុំជម្រះសាលាដំបូងប្រកាសថា សវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ មិន

ទាន់បិទបញ្ចប់នៅឡើយទេ រហូតដល់អង្គជំនុំជម្រះតុលាការកំពូលសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខនោះ។

ទោះជាយ៉ាងនេះក្ដី ក្នុងរយៈពេលរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលនឹងផ្ដល់គោលការណ៍ណែនាំបន្ថែមទៀតលើចំណុចនេះនោះ។ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសកាលបរិច្ឆេទបណ្ដោះអាសន្នរបស់ខ្លួនដូចខាងក្រោមនេះ៖

សារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវដាក់ជូនយ៉ាងយូរបំផុតត្រឹមថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣ ដោយអាចដាក់ជាបឋមជាភាសាណាមួយរបស់ អ.វ.ត.ក ហើយដាក់ឯកសារបកប្រែតាមក្រោយ។

សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវចាប់ផ្ដើមធ្វើនៅថ្ងៃទី០៩ ខែតុលា ២០១៣ រហូតដល់បញ្ចប់នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ដោយដំណើរការទាំងថ្ងៃសុក្រផងដែរ។

អង្គជំនុំជម្រះសម្រេចជ្រើសរើសយកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ជាថ្ងៃចាប់ផ្ដើមសវនាការលើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយយោងទៅលើភាពស្មុគស្មាញក្នុងការរៀបចំកាលបរិច្ឆេទនៅក្នុងខែតុលានេះ ដែលមានថ្ងៃឈប់សម្រាកច្រើន។

[១៥:២១:១៨]

យោងតាមការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ជាផ្លូវការថា តម្កល់ ឬកែប្រែនូវការកំណត់កាលបរិច្ឆេទខាងលើនេះ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខ។

តាមសំអាងហេតុដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនចេញសេចក្ដីសម្រេចស្ដាពររបស់ខ្លួនអំពីសាក្សី សាក្សីអ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវស្ដាប់នៅក្នុងសំណុំរឿង០០២/០១នោះទេ។ ហើយសេចក្ដីសម្រេចនេះនឹងត្រូវយកទៅដាក់បញ្ចូលនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះជាជាងចេញសេចក្ដីសម្រេចដាច់ដោយឡែកនៅពេលខាងមុខនេះ។

អង្គជំនុំជម្រះកត់សម្គាល់ថា ភាគីទាំងអស់នេះទទួលបាននូវឯកសារចម្លងនៃឧបសម្ព័ន្ធទាំងអស់នៃសេចក្ដីសម្រេចនេះរួចរាល់ហើយ ហើយព័ត៌មានដែលមាននៅក្នុងឧបសម្ព័ន្ធទាំងអស់នោះមិនមានការកែប្រែនោះទេ។

[១៥:២២:២៧]

ជាចុងក្រោយនេះពាក់ព័ន្ធទៅនឹងសារណាបញ្ចប់ការពិភាក្សាដេញដោល អង្គជំនុំជម្រះឯកភាពផ្ដល់ជូនភាគីនីមួយៗ ចំនួន២៥ទំព័របន្ថែមទៀតដើម្បីឆ្លើយតបចំពោះភស្តុតាង ឬឯកសារបន្ថែមដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមសេចក្ដីសម្រេចស្ដាពរលើភស្តុតាងរបស់អង្គជំនុំជម្រះ។

ហេតុដូច្នេះសហព្រះរាជអាជ្ញាទទួលបាន២២៥ទំព័រ សម្រាប់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ ជនជាប់ចោទនីមួយៗ ទទួលបាន១២៥ទំព័រ ហើយដើមបណ្ដឹងរដ្ឋប្បវេណីទទួលបាន១០៥ទំព័រ ដោយមិនរាប់បញ្ចូលនូវសារណាស្ដីពីសំណង។

អង្គជំនុំជម្រះសាលាដំបូងបញ្ចប់សេចក្ដីសម្រេចផ្ទាល់មាត់ត្រឹមនេះ ហើយអង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណដល់ភាគីទាំងអស់ ដែលបានជួយសហការជាមួយនឹងអង្គជំនុំជម្រះលើបញ្ហាទាំងអស់នេះ។

ហើយនៅថ្ងៃនេះអង្គជំនុំជម្រះ កិច្ចដំណើរការសវនាការគឺដល់ពេលសម្រាកហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

[១៥:២៤:៥៨]

ហើយ -- មិនមានបញ្ហា -- មិននិយាយអីទៀតទេណ៎!

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ឯដីកាកោះ និងដីកាបង្គាប់ឲ្យយកខ្លួនគាត់មកចូលរួមនៅក្នុងសវនាការនាពេលខាងមុខ អង្គជំនុំជម្រះនឹងចេញនៅពេលសមស្រប ឲ្យបានមុនកាលបរិច្ឆេទសវនាការដែលអង្គជំនុំជម្រះនឹងកំណត់ -- ដែលបានកំណត់ខាងលើរួចហើយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង១៥:២៥នាទី)*